Berlin Center for the Treatment of Torture Victims

bzfo
Behandlungszentrum
für Folteropfer Berlin

# The Survivors' Voices: Attitudes on the ECCC, the Former Khmer Rouge and Experiences with Civil Party Participation

DECEMBER 2010







NADINE STAMMEL
SEBASTIAN BURCHERT
SOPHEAP TAING
ESTELLE BOCKERS
CHRISTINE KNAEVELSRUD

# សម្លេងអ្នកនៅរស់រានមានជីវិតៈ
# ឥរិយាបទចំពោះអវតក
# ចំពោះអតីតពួកខ្មែរក្រហម
# និងចំពោះការចូលរួមជា
# ដើមបណ្តឹងរដ្ឋប្បវេណី

bzfo
Behandlungszentrum
für Folteropfer Berlin


NADINE STAMMEL
SEBASTIAN BURCHERT
តាំង សុភាព
ESTELLE BOCKERS
CHRISTINE KNAEVELSRUD

មជ្ឈមណ្ឌលបៃតងរំលែកសម្រាប់ការព្យាបាលជនរងគ្រោះពីអំពើទារុណកម្ម (bzfo) ត្រូវបានបង្កើតឡើង
ក្នុងឆ្នាំ១៩៩២ ដោយ
មានការឧបត្ថម្ភគាំទ្រពីភាគបាទក្រហមនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ bzfo ជាសមាគមមិន
រកប្រាក់កម្រៃមួយ ដែលប្តូរផ្តាច់ក្នុងការស្តារនីតិសម្បទារបស់ជនរងគ្រោះពីអំពើទារុណកម្ម។

ការអង្កេតបង្ហាញក្នុងរបាយការណ៍នេះត្រូវបានរៀបចំឡើង ដោយមានកិច្ចសហការជាមួយអង្គការចិត្តសង្គ
ម អន្តរវប្បធម៌ ហៅកាត់ អង្គការធី-ភី-អូ (កម្ពុជា)

ការអង្កេតទាំងពីរអាចដំណើរការទៅបានក៏ដោយសារជំនួយថវិកាពីក្រសួងការបរទេសនៃសាធារណរដ្ឋស
ហព័ន្ធអាល្លឺម៉ង់និងអង្គការចិត្តសាស្រ្ត
គ្មានព្រំដែន(PBB)។ ទីភ្នាក់ងារផ្តល់មូលនិធិមិនបានចូលរួមក្នុងការរៀបចំ អនុវត្ត វិភាគ ឬចងក្រង
លទ្ធផលក្នុងរបាយការណ៍នេះឡើយ។ ព័ត៌មានផ្តល់ជូន និង
ទស្សនៈដែលឆ្លុះបញ្ចាំងក្នុងការបោះពុម្ពផ្សាយនេះជារបស់អ្នកចងក្រងរបាយការណ៍នេះ គឺមិន
មែនតំណាងឲ្យទីភ្នាក់ងារផ្តល់មូលនិធិខាងលើឡើយ។

# មាតិកា


០. សេចក្តីសង្ខេបទូទៅ......5

១. សេចក្តីផ្តើម......7

៣. ការសិក្សាជាមួយអ្នករួចជីវិតផ្ទាល់ (២០០៨-២០០៩)......9

៣.១ វិធីសាស្ត្រ......9

៣.២ ខ្វាតវ៉ាស់វែង......11

៣.៣ លទ្ធផល......12

៤. ការសិក្សាជាមួយអ្នកដាក់ពាក្យ (២០១០)......24

៤.១ វិធីសាស្ត្រ......24

៤.២ ខ្នាតវ៉ាស់វែង......26

៤.៣ លទ្ធផល......26

៦. ស្នេរ និងសេចក្តីថ្លែងអំណរគុណ......59

# ០. សេចក្តីសង្ខេបទូទៅ

របាយការណ៍នេះពណ៌នាអំពីរបកគំហើញនៃការសិក្សាអង្កេតចំនួនពីរ ដែលបានរៀបចំធ្វើនៅកម្ពុជា។ ការសិក្សាទីមួយបានធ្វើនៅចន្លោះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩។ អ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះ គឺអ្នកដែលបានកើតមុនឆ្នាំ១៩៧៥ និងបានចាត់ទុកខ្លួនគេថា ជាជនរងគ្រោះនៃរបបខ្មែរក្រហម។ អ្នកចូលរួមផ្តល់សម្ភាសន៍សរុបមាន១០៧៧នាក់។ ប្រមាណមួយភាគបួននៃអ្នកចូលរួមផ្តល់សម្ភាសន៍ គឺ២៤៧នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើម-បណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅកាត់ អវតក។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម-បណ្តឹងរដ្ឋប្បវេណីទាំងនេះស្ថិតក្នុងចំណោមជនរងគ្រោះដំបូងៗគេបង្អស់ ដែលបានដាក់ពាក្យនៅចំពោះមុខអវតក។ យើងបានសួរអ្នកចូលរួមផ្តល់សម្ភាសន៍អំពីឥរិយាបទរបស់ពួកគាត់ចំពោះអតីតខ្មែរក្រហម ចំពោះអវតក ចំពោះសំណង និងចំពោះការត្រៀមខ្លួនរបស់ពួកគេក្នុងការផ្សះផ្សាជាមួយនឹងជនដៃដល់។ បន្ថែមលើនេះទៀត យើងខ្ញុំបានសម្ភាសជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-វេណីអំពីមូលហេតុនៃការចូលរួមរបស់ពួកគេក្នុងដំណើរការនីតិវិធីរបស់តុលាការ។

នៅក្នុងការអង្កេតលើកទីពីរ ដែលបានធ្វើនៅចន្លោះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ និងថ្ងៃទី១០ខែធ្នូ ឆ្នាំ២០១០កន្លងទៅនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្ភាសជាថ្មីម្តងទៀត។ ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៤៧នាក់ពីការអង្កេតលើកទីមួយ ៩១.៥% (២២៦នាក់) អាចត្រូវបានសម្ភាសជាថ្មីម្តងទៀត។

គោលបំណង គឺដើម្បីស្វែងយល់អំពីផលប៉ះពាល់នៃការដាក់ពាក្យ និងការចូលរួមក្នុងដំណើរការនីតិវិធីរបស់អវតកទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ និងទៅលើក្រុមគ្រួសាររបស់ពួកគេ និងដើម្បីស្វែងយល់អំពីប្រភពនៃការគាំទ្រផ្នែកចិត្តសង្គម និងផ្នែកច្បាប់ ចំណេះដឹងអំពីដំណើរការនីតិវិធី និងពិសេស ការយល់ឃើញទៅលើការជំនុំជម្រះសំណុំរឿងទីមួយប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច។ របកគំហើញចម្បងៗដែលយើងខ្ញុំទទួលបាន មានដូចខាងក្រោមៈ

ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ពួកគេត្រេកអរចំពោះអវតក។ រីឯការអង្កេតបន្ទាប់បង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញនូវផលវិបាកអវិជ្ជមាន ពាក់ព័ន្ធនឹងការដាក់ពាក្យរបស់ពួកគេឡើយ។ បន្ថែមលើនេះទៀត ពួកគេហាក់ដូចជាមានទំនុកចិត្តទៅលើតុលាការ និងបានបង្ហាញអំពីការពេញចិត្តពេញថ្លើមនឹងការងាររបស់តុលាការនេះ។ អ្នកចូលរួមផ្តល់សម្ភាសន៍ជាច្រើនរំពឹងថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សា និងថែមទាំង

បានបញ្ជាក់ថា តុលាការនេះបានដឹកនាំទៅរកនិន្នាការដ៏សម្បើមមួយក្នុងការផ្សះផ្សាក្នុងចំណោមពួកគេ។ ជាទូទៅ មូលហេតុចម្បងនៃការដាក់ពាក្យ គឺដើម្បីស្វែងរកយុត្តិធម៌ និងដើម្បីសងសឹកចំពោះអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

អ្នកចូលរួមផ្តល់សម្ភាសន៍ភាគច្រើនបានចាត់ទុកថា សំណងជាបញ្ហាដ៏សំខាន់មួយ។ ផ្ទុយពីវិធានផ្ទៃក្នុងរបស់អវតក មនុស្សជាច្រើនចង់បានសំណងជាថវិកាលក្ខណៈបុគ្គលជាជាងសំណងសមូហភាព ឬផ្លូវចិត្ត។ យ៉ាងណាមិញ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រាថ្នាចង់ធ្វើបុណ្យឧទ្ទិសដល់សមាជិកក្រុមគ្រួសារដែលបានស្លាប់ច្រើនជាងអ្នកនៅរស់រានជីវិត ដែលមិនបានដាក់ពាក្យនៅអវតក។

ដើមបណ្តឹងរដ្ឋប្បវេណីមានការពេញចិត្តពេញថ្លើមនឹងការជួយគាំទ្រ ដែលពួកគេទទួលបានពីមេធាវី និងក្រុមគ្រួសាររបស់ខ្លួន។ អ្នកចូលរួមផ្តល់សម្ភាសន៍ជាច្រើនចង្អុលបង្ហាញថា ពួកគេបានតាមដានដំណើរការនីតិវិធីនៅអវតក។ ទោះជាយ៉ាងនេះក្តី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនហាក់ដូចជាខ្វះខាតព័ត៌មានស្តីពីការដាក់ពាក្យរបស់ខ្លួន និងដំណើរការនីតិវិធីនៅតុលាការ។

យ៉ាងណាមិញ ការជំនុំជម្រះសំណុំរឿងទីមួយប្រឆាំងនឹងឌុច និងសាលក្រមសម្រាប់សំណុំរឿងទីមួយនេះត្រូវបានទទួលយកយ៉ាងវិជ្ជមាន។ យើងខ្ញុំបានរកឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីអតីតកាលដ៏សែនឈឺចាប់របស់ខ្លួនតែជាមួយក្រុមគ្រួសាររបស់ខ្លួន និងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះ។ ពួកគេភាគច្រើនចាត់ទុកការធ្វើបុណ្យឧទ្ទិសដល់អ្នកដែលបានស្លាប់ និងការចងក្រងទុកជាឯកសារនូវរឿងរ៉ាវរបស់ពួកគេជាវិធានការដ៏មានសារៈសំខាន់មួយក្នុងការជួយបន្ធូរបន្ថយការឈឺចាប់របស់ពួកគេ។

# ១. សេចក្តីផ្តើម

ជាលើកដំបូងបង្អស់ ហើយជាង៣០ឆ្នាំបន្ទាប់ពីព្រឹត្តិការណ៍ដ៏មហាបំផ្លិតបំផ្លាញ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) អតីតជនល្មើសកំពុងត្រូវបាននាំខ្លួនមកចំពោះមុខតុលាការផ្លូវការមួយ ដែលអនុវត្តតាមបទដ្ឋានច្បាប់អន្តរជាតិ នោះគឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)។ អវតកតំណាងឲ្យកិច្ចខិតខំប្រឹងប្រែងដ៏ពិសេសមួយក្នុងការស្វែងរកយុត្តិធម៌អន្តរជាតិ ក៏ដូចជាក្នុងប្រព័ន្ធច្បាប់ជាតិរបស់កម្ពុជា។ យុទ្ធសាស្ត្រថ្មីមួយធ្វើឲ្យតុលាការនេះខុសប្លែកពីតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិមុនៗ។ អវតកមានទីតាំងនៅកម្ពុជា ហើយមានបុគ្គលិកជាតិ និងអន្តរជាតិ ហើយយកមកអនុវត្តនូវច្បាប់ជាតិផង និងច្បាប់អន្តរជាតិផង ជាយុទ្ធសាស្ត្របែបតុលាការកូនកាត់មួយ។

ជាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មសង្គ្រាម ដែលជនរងគ្រោះត្រូវបានអនុញ្ញាតឲ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការនីតិវិធីរបស់តុលាការ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។

បន្ថែមលើនេះទៀត អវតកជាតុលាការអន្តរជាតិដំបូងគេបង្អស់ ដែលមានអាណត្តិផ្តល់សំណង។

លក្ខណៈពិសេសខាងលើរបស់អវតកផ្តល់នូវឱកាសថ្មីៗដល់ការចូលរួមកាន់តែមានលក្ខណៈទូលំទូលាយរបស់ប្រជាជន ដែលទទួលប៉ះពាល់ និងផ្តល់នូវបរិយាកាសមួយដែលមានគោលបំណងនាំមកនូវយុត្តិធម៌ឲ្យប្រជាជន។

របាយការណ៍នេះភ្ជាប់មកនូវរបកគំហើញរបស់ការអង្កេតពីរ ដែលបានរៀបចំឡើងជាមួយអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។

ការអង្កេតទីមួយមានការចូលរួមពីអ្នកផ្តល់សម្ភាសន៍១០៧៧នាក់ មកពីខេត្ត-ក្រុងនានានៅកម្ពុជា ហើយធ្វើឡើងក្នុងចន្លោះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨ និង ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ រហូតទល់នឹងការជំនុំជម្រះរឿងក្តីទីមួយរបស់តុលាការ។

សំណួរចម្បងៗក្នុងការអង្កេតទីមួយនេះរួមមាន:

- តើហេតុការណ៍អ្វីដែលអ្នកចូលរួមផ្តល់សម្ភាសន៍បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម?
- នាបច្ចុប្បន្ន តើពួកគេយល់ឃើញយ៉ាងណាដែរចំពោះអតីតខ្មែរក្រហម?
- តើឥរិយាបទ និងការរំពឹងទុកអ្វីខ្លះ ដែលពួកគេមាន ពាក់ព័ន្ធនឹងការជំនុំជម្រះ?
- តើពួកគេមានមតិយោបល់អ្វីខ្លះ ពាក់ព័ន្ធនឹងសំណង និងសំណងអ្វីខ្លះដែលបានទាមទារ?

ក្នុងចំណោមអ្នកចូលរួមផ្តល់សម្ភាសន៍ ១០៧៧ នាក់ ប្រមាណមួយភាគបួនបានដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីនៅអវតក។

ការអង្កេតមួយទៀតបានចាប់ផ្តើមនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ និងបានបញ្ចប់នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ថ្មីៗនេះ។ ក្នុងនោះ អ្នកផ្តល់ចម្លើយដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្ភាសជាថ្មីម្តងទៀត គឺបន្ទាប់ពីការផ្តល់សម្ភាសន៍លើកទីមួយ ប្រមាណ១ឆ្នាំ ៧ខែ។

ក្នុងការអង្កេតលើកទីពីរនេះ យើងបានធ្វើបទសម្ភាសន៍ចំនួន២២៦។

បន្ទាប់ពីការចេញសាលក្រមសម្រាប់សំណុំរឿងទីមួយ និងផែនការជំនុំជម្រះសំណុំរឿងទីពីរក្នុងឆ្នាំ២០១០ យើងខ្ញុំបានផ្តោតទៅលើសំណួរខាងក្រោម ហើយដែលជាផ្នែកសំខាន់នៃរបាយការណ៍នេះ។

- តើអ្នកនៅរស់រានមានជីវិត ទទួលបានបទពិសោធន៍អ្វីខ្លះ ពាក់ព័ន្ធនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅអវតក (កម្មវិធីផ្សព្វផ្សាយ ការគាំទ្រដោយអង្គការនានា និង មេធាវី)?
- តើសកម្មភាពរបស់ពួកគេ ពាក់ព័ន្ធនឹងអវតក មានការប៉ះពាល់នៅកម្រិតណាដែរទៅលើជីវិតរបស់ពួកគេ ឬជីវិតរបស់ក្រុមគ្រួសារពួកគេ?
- តើពួកគេមានឥរិយាបទដូចម្តេចដែរចំពោះការជំនុំជម្រះក្នុងសំណុំរឿងទីមួយ និងសាលក្រមសម្រាប់សំណុំរឿងទីមួយនេះ?
- តើអ្នកនៅរស់រានមានជីវិតបានស្វែងរកការគាំទ្រផ្នែកចិត្តសង្គមប្រភេទណាខ្លះ ក្នុងការសម្របខ្លួនរស់នៅជាមួយនឹងអតីតកាលដ៏ឈឺចាប់របស់ពួកគេ?

របាយការណ៍នេះត្រូវបានរៀបចំជាប្រាំជំពូក។ ជំពូកទី២ផ្តោតទៅលើព័ត៌មានស្តីពីរបបខ្មែរក្រហម អវតក ការចូលរួមរបស់ជនរងគ្រោះ និងសំណងក្នុងបរិបទនៃតុលាការ។ ក្នុងជំពូកទី៣ មានការបង្ហាញអំពីវិធីសាស្ត្រ និងរបកគំហើញនៃការសិក្សាអង្កេតទីមួយ។ ជំពូកទី៤ មានការបង្ហាញលទ្ធផលថ្មីៗបានមកពីការសិក្សាអង្កេតទីពីរ។ ចុងក្រោយ ក្នុងជំពូកទី៥ មានសេចក្តីសង្ខេបស្តីពីរបកគំហើញចម្បងៗ និងការពិភាក្សាមួយពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

# ៣. ការសិក្សាជាមួយអ្នកនៅរស់រានមានជីវិតផ្ទាល់(០៨-០៩)

## ៣.១ វិធីសាស្ត្រ

*របាយជ្រើសរើសប៉ាន់គំរូ*

ចំនួនសរុបនៃអ្នកផ្តល់សម្ភាសន៍មាន១០៧៧នាក់ មកពី១៩ខេត្ត-ក្រុងនៃប្រទេសកម្ពុជា ដូចមាន ការចង្អុលបង្ហាញក្នុងតារាងខាងក្រោម។

**តារាង១០: អ្នកចូលរួមផ្តល់សម្ភាសន៍តាមខេត្តនីមួយៗ**

| | (%) |
|---|---|
| កណ្តាល | 23.2 |
| ភ្នំពេញ | 17.4 |
| តាកែវ | 7.2 |
| កំពត | 6.3 |
| កំពង់ស្ពឺ | 5.1 |
| ស្វាយរៀង | 4.2 |
| បាត់ដំបង | 4.0 |
| កំពង់ចាម | 4.9 |
| ពោធិសាត់ | 3.5 |
| សៀមរាប | 3.0 |
| ស្ទឹងត្រែង | 3.0 |
| ព្រះសីហនុ | 3.0 |
| រតនគិរី | 2.9 |
| កោះកុង | 2.9 |
| កំពង់ធំ | 2.7 |
| កំពង់ឆ្នាំង | 2.6 |
| ក្រចេះ | 2.6 |
| បន្ទាយមានជ័យ | 1.5 |
| ប៉ៃលិន | 0.9 |

ក្នុងចំណោមអ្នកចូលរួមផ្តល់សម្ភាសន៍ទាំងអស់ ២៣% (២៤៧នាក់) បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងមួយ ឬសំណុំរឿងទាំងពីរនៅអវតក។

*អ្នកធ្វើសម្ភាសន៍*

បទសម្ភាសន៍ត្រូវបានធ្វើឡើងដោយអ្នកធ្វើសម្ភាសន៍កម្ពុជា ដែលមានបរិញ្ញាបត្រផ្នែកចិត្តវិទ្យា។ មុននឹងចាប់ផ្តើមការអង្កេតលើកទីមួយនេះ អ្នកធ្វើសម្ភាសន៍បានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍មួយស្តីពីផលវិបាកផ្នែកផ្លូវចិត្តនៃសង្គ្រាម និងការប៉ះទង្គិចផ្លូវចិត្ត ការវិភាគអំពីជម្ងឺផ្លូវចិត្តពាក់ព័ន្ធនានា បច្ចេកទេសសម្ភាសន៍ ក៏ដូចជា សាវតារបស់អវតក និងរបបខ្មែរក្រហម។

ក្នុងអំឡុងពេលបណ្តុះបណ្តាលនេះ ការយកមកអនុវត្តនូវតារាងសំណួរត្រូវបានយកមកបង្រៀនគួបផ្សំនឹងទស្សនាទានពាក់ព័ន្ធនានា ហើយខ្លឹមសារនៃតារាងសំណួរសម្រាប់អនុវត្តត្រូវបានយកមកពិភាក្សា និងកែសម្រួល ប្រសិនបើចាំបាច់។ ក្នុងអំឡុងពេលនៃការធ្វើអង្កេត អ្នកធ្វើសម្ភាសន៍ត្រូវបានត្រួតពិនិត្យតាមដានផ្ទាល់ដោយអ្នកជំនាញចិត្តវិទ្យាពីររូប។

*នីតិវិធី*

ការជ្រើសរើសអ្នកចូលរួមផ្តល់សម្ភាសន៍អនុវត្តទៅតាមវិធីសាស្រ្តពីរដំណាក់កាលៈ

ដំបូងឡើយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទំនាក់ទំនង ដោយមានជំនួយពីសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (Adhoc) និងស្នើសុំឲ្យចូលរួមក្នុងការអង្កេតនេះ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានទំនាក់ទំនងដោយសមាគមអាដហុក ក្នុងដំណាក់កាលដំបូងៗនៃសកម្មភាពផ្សព្វផ្សាយរបស់គេ និងបានដាក់ពាក្យបណ្តឹងទៅកាន់អវតករួចរាល់ហើយ។ នេះមានន័យថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានចូលរួមក្នុងការអង្កេតនេះជាអ្នកដំបូងៗគេបង្អស់ក្នុងចំណោមជនរងគ្រោះ ដែលបានដាក់ពាក្យនៅតុលាការ។

ក្រៅពីនេះ អ្នកចូលរួមផ្តល់សម្ភាសន៍ផ្សេងទៀត ត្រូវបានជ្រើសរើសដោយប្រើប្រាស់វិធីសាស្រ្តជ្រើសរើសប៉ាន់គំរូងាយស្រួល។

ក្នុងនោះ បទសម្ភាសន៍ចំនួន ១២០ត្រូវបានធ្វើឡើងនៅតាមភូមិ ដែលអង្គការដៃគូ គឺអង្គការចិត្តសង្គម អន្តរវប្បធម៌ (អង្គការធីភីអូ កម្ពុជា) កំពុងធ្វើការនៅទីនោះ ក៏ដូចជានៅគ្លីនិកសម្រាប់អ្នកជម្ងឺមកពិគ្រោះជម្ងឺក្រៅ របស់អង្គការធីភីអូ កម្ពុជា នៅរាជធានីភ្នំពេញ។ ចំណែកឯអ្នកចូលរួមផ្តល់សម្ភាសន៍ផ្សេងៗទៀត ត្រូវបានជ្រើសរើសតាមភូមិផ្សេងៗនៅកម្ពុជា ដែលយើងខ្ញុំបានចុះទៅ ដើម្បីធ្វើសម្ភាសន៍ទាំងនេះ។

អ្នកចូលរួមផ្តល់សម្ភាសន៍ទាំងអស់ដែលអាចចូលរួមបានត្រូវតែកើតមុនឆ្នាំ១៩៧៥ និងចាត់ទុកថាខ្លួនជាជនរងគ្រោះនៃរបបខ្មែរក្រហម។ មិនមានលក្ខណៈវិនិច្ឆ័យនៃការផាត់ចោលត្រូវបានយកមកអនុវត្តឡើយ។

ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលត្រូវបានទំនាក់ទំនងស្នើសុំឲ្យចូលរួមផ្តល់សម្ភាសន៍ក្នុងការអង្កេត ៨២០នាក់បដិសេធមិនផ្តល់សម្ភាសន៍។ បន្ថែមលើនេះទៀត មានប្រាំករណី បទសម្ភាសន៍មិនអាចបញ្ចប់ទៅបាន ដោយសារតែបញ្ហាលំបាកផ្នែកភាសា កង្វះខាតពេលវេលា ឬកម្រិតនៃភាពតានតឹងផ្នែកអារម្មណ៍កើតឡើងចំពោះអ្នកផ្តល់សម្ភាសន៍។ អ្នកចូលរួមផ្តល់សម្ភាសន៍ទាំងប្រាំនាក់នេះមិនត្រូវបានរាប់ចូលក្នុងការវិភាគទិន្នន័យឡើយ។

អ្នកចូលរួមផ្តល់សម្ភាសន៍ត្រូវបានសម្ភាសជាលក្ខណៈជួបមុខផ្ទាល់ ដោយប្រើប្រាស់ភាសាខ្មែរ នៅចន្លោះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨ និងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩។

មុននឹងធ្វើបទសម្ភាសន៍នីមួយៗ អ្នកចូលរួមត្រូវបានផ្តល់ព័ត៌មានអំពីចំណុចខាងក្រោម និងត្រូវផ្តល់ការព្រមព្រៀងផ្ទាល់មាត់ជាមុន។

- លក្ខណៈស្ម័គ្រចិត្តទាំងស្រុងនៃបទសម្ភាសន៍
- រយៈពេល និងប្រធានបទនៃបទសម្ភាសន៍
- សិទ្ធិក្នុងការបដិសេធមិនឆ្លើយសំណួរណាមួយ ក៏ដូចជា សិទ្ធិក្នុងការបញ្ចប់បទសម្ភាសន៍ក្នុងពេលណាក៏បាន
- គោលការណ៍នៃការរក្សាការសម្ងាត់ និង អនាមិកភាព។

អ្នកធ្វើសម្ភាសន៍ត្រូវបានណែនាំ ដើម្បីធានាថា មានទីតាំងសមស្របសម្រាប់សម្ភាសន៍ ដែលអាចផ្តល់នូវភាពឯកជនចាំបាច់។ គ្មានការផ្តល់អំណោយហិរញ្ញវត្ថុដល់អ្នកផ្តល់បទសម្ភាសន៍ចំពោះការចូលរួមរបស់ពួកគេក្នុងការអង្កេតនេះទេ។ ទោះជាយ៉ាងនេះក្តី នៅចុងបញ្ចប់បទសម្ភាសន៍នីមួយៗ កាដូដ៏តូចមួយ ក្នុងនោះមាន សាប៊ូមួយដុំ និងក្រម៉ាមួយ ត្រូវបានផ្តល់ជូន ប៉ុន្តែយើងខ្ញុំមិនបានប្រាប់អ្នកផ្តល់សម្ភាសន៍អំពីកាដូនេះ មុនពេលធ្វើបទសម្ភាសន៍ឡើយ។

ជាមធ្យម បទសម្ភាសន៍នីមួយៗត្រូវការរយៈពេល១ម៉ោង កន្លះ។

## ៣.២ ខ្នាតវាស់វែង

ខ្នាតវាស់វែងត្រូវបានបង្កើតឡើងក្នុងក្រុមការងារ។

សំណួរទាំងអស់ត្រូវបានបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ដោយអ្នកជំនាញចិត្តសាស្ត្រកម្ពុជា និងបកប្រែត្រឡប់ទៅជាភាសាអង់គ្លេសវិញ ដោយអ្នកបកប្រែ ដែលមិនបានដឹងអំពីសំណៅដើមជាភាសាអង់គ្លេសឡើយ ដើម្បីផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃការបកប្រែជាមួយនឹងអត្ថបទដើម។

បន្ថែមលើនេះទៀត សំណួរចំនួនបួនស្តីពីឥរិយាបទចំពោះសំណង បង្កើតឡើងដោយ Pham et al. (2009 ) ក៏ត្រូវបានដាក់បញ្ចូលផងដែរ[57]។

## ៣.៣ លទ្ធផល

*ការបង្ហាញ និងការវិភាគទិន្នន័យ*

ទិន្នន័យត្រូវបានវិភាគ ដោយប្រើប្រាស់កម្មវិធី Statistical Package for Social Sciences (SPSS) កំណែ 17.0 ។

ជាទូទៅ លទ្ធផលក្នុងជំពូកនេះត្រូវបានបង្ហាញតាមរបៀបដាច់ដោយឡែកពីគ្នា ពោលគឺបង្ហាញជាភាគរយក្នុងក្រុមនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (២៤៧នាក់ ជា “អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី”) និងក្រុមនៃអ្នកផ្តល់សម្ភាសន៍ ដែលមិនបានចូលរួមក្នុងដំណើរការនីតិវិធីនៃអវតក (សរុប៨៣០នាក់ ជា “អ្នកមិនចូលរួមក្នុងដំណើរការនីតិវិធីនៃអវតក”)។ ជាញឹកញាប់ ក្រុមទាំងពីរនេះត្រូវបានបង្ហាញ ដោយប្រៀបធៀបទៅនឹងប៉ាន់គំរូទាំងមូល (សរុប១០៧៧ ជា “ចំនួនសរុប”)។

ពេលណា មានពិន្ទុសរុបដាច់ដោយឡែកមួយ ឬតែមួយ ជាទូទៅគឺវាសំដៅទៅលើភាគរយក្នុងក្រុមរួមបញ្ចូលគ្នានៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកមិនចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ (សរុប ១០៧៧)។

*ប្រជាសាស្ត្រសង្គម*

ជាមធ្យម អ្នកចូលរួមផ្តល់សម្ភាសន៍មានអាយុ ៥៦.២ ឆ្នាំ គឺពួកគេមានអាយុចន្លោះពី៣៥ទៅ៩៨ឆ្នាំ។ ៦១.៧ភាគរយនៃប៉ាន់គំរូជាស្ត្រី។ ពីរភាគបីនៃអ្នកផ្តល់សម្ភាសន៍បានរៀបការ និងប្រមាណមួយភាគបីជាស្ត្រីមេម៉ាយ។ ប្រមាណ៨៩ភាគរយជាខ្មែរជនជាតិដើមភាគតិច ហើយ៩២ភាគរយបានប្រាប់ថាខ្លួនកាន់ព្រះពុទ្ធសាសនា។ ជាមធ្យម អ្នកចូលរួមផ្តល់សម្ភាសន៍បានចំណាយពេលរៀនសូត្របួនឆ្នាំ។ ប្រមាណ៣៨ភាគរយអះអាងថា ខ្លួនអាចអាន និងសរសេរបាន ខណៈដែលប្រមាណ៣១ភាគរយថាខ្លួនជាអនក្ខរជន។

[57] Pham, P., Vinck, P., Balthazard, M., Hean, S. & Stover, E. (2009). ដូច្នេះយើងនឹងមិនភ្លេចទេ។ ការអង្កេតដែលផ្អែកទៅលើចំនួនប្រជាជន ស្តីពីឥរិយាបទចំពោះការកសាងសង្គម និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**តារាង២០: ប្រជាសាស្ត្រសង្គម**

| **ទំហំប៉ាន់គំរូ (n)** | **% ស្ត្រី** | **អាយុ (S.D.)** | **ស្ថានភាពគ្រួសារ** | | | | |
|---|---|---|---|---|---|---|---|
| | | | រៀបការ | មេម៉ាយ | លែងលះ | នៅលីវ | ផ្សេងៗ |
| 1077 | 61.7 | 56.2 (10.2) | 66.2 | 27.9 | 2.8 | 1.6 | 1.5 |

| **របាយអាយុ (%)** | | | | **ការអប់រំ** | | | |
|---|---|---|---|---|---|---|---|
| 35–44 ឆ្នាំ | 45–54 ឆ្នាំ | 55–64 ឆ្នាំ | > 65 ឆ្នាំ | ឆ្នាំសិក្សា (S.D.) | អក្ខរកម្ម (%) | | |
| | | | | | បាទ | តិចតួច | ទេ |
| 13.6 | 31.3 | 32.3 | 22.8 | 3.9 (3.6) | 38.3 | 30.5 | 31.2 |

| **ជនជាតិដើមភាគតិច (%)** | | | | **ជំនឿផ្នែកសាសនា (%)** | | | |
|---|---|---|---|---|---|---|---|
| ខ្មែរ | ចាម | ចិន | ផ្សេងៗ | ព្រះពុទ្ធ | អុីស្លាម | គ្រីស្ទ | ផ្សេងៗ |
| 89.1 | 4.5 | 1.7 | 4.7 | 92.2 | 5.8 | 1.7 | 0.3 |

*ព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្ត*

ការពើបប្រទះនឹងព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្តមានលក្ខណៈទូលំទូលាយនៅក្នុងរបបខ្មែរក្រហម។ ព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្តអាចជាការឆ្លងកាត់ផ្ទាល់ ឬបានឃើញរបស់អ្នកផ្តល់សម្ភាសន៍។ ទិន្នន័យនេះបង្ហាញអំពីព្រឹត្តិការណ៍អាយុកាលនៃប៉ាន់គំរូ និងដូច្នេះ រាប់បញ្ចូលទាំងព្រឹត្តិការណ៍ដែលបានកើតឡើងមុន និងបន្ទាប់ពីការគ្រប់គ្រងរបស់របបខ្មែរក្រហម។ យ៉ាងណាមិញ ព្រឹត្តិការណ៍ភាគច្រើនត្រូវបានរាយការណ៍ថា បានកើតឡើងស្ទើតែទាំងអស់ក្នុងអំឡុងរបបខ្មែរក្រហម។

ស្ទើតែគ្រប់អ្នកផ្តល់សម្ភាសន៍បានឃើញ និងឆ្លងកាត់ផ្ទាល់នូវកង្វះខាតម្ហូបអាហារ ហើយផ្តល់សម្ភាសន៍ច្រើនជាង៩២%ត្រូវបានបង្ខំឲ្យធ្វើការ ឬបានឃើញព្រឹត្តិការណ៍ទាំងនេះកើតឡើងចំពោះអ្នកដទៃ។ យ៉ាងហោចណាស់អ្នកផ្តល់សម្ភាសន៍បីភាគបីរាយការណ៍ថាបានឃើញ ឬបានរងគ្រោះពីការពង្រាត់ពីក្រុមគ្រួសារ ការជម្លៀសដោយបង្ខំ និងស្ថានភាពនៃការវាយប្រយុទ្ធគ្នា។

យ៉ាងណាមិញ ស្ថានភាពនៃការវាយប្រយុទ្ធគ្នាអាចរាប់បញ្ចូលនូវហេតុការណ៍នៃសង្គ្រាមវៀតណាម ដែលបានកើតឡើងមុនឆ្នាំ១៩៧៥ ឬក្នុងអំឡុងការតស៊ូផ្នែកនយោបាយផ្ទៃក្នុង ដែលកើតមានឡើងបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ។

ការបង្ខំឲ្យរៀបការដោយអង្គការ ដែលជាពាក្យមួយសំដៅទៅលើថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គឺមានភាពទូលំទូលាយជាខ្លាំង ដោយថាស្ទើរតែពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍ចង្អុលបង្ហាញថា យ៉ាងហោចណាស់ ខ្លួនបានឃើញការរៀបការដោយបង្ខំ។ សរុបទៅ ១៥.១%នៃអ្នកផ្តល់សម្ភាសន៍រាយការណ៍ថា ខ្លួនគេផ្ទាល់ត្រូវបានបង្ខំឲ្យរៀបការដោយអង្គការ។ ដោយហេតុថាអ្នកផ្តល់សម្ភាសន៍ភាគច្រើនបានរៀបការហើយក្នុងរបបនោះ ឬក៏ក្មេងខ្លាំងពេកនឹងរៀបការ ចំនួននេះពិតជាខ្ពស់

ល្មមគួរសម។ គួរឲ្យភ្ញាក់ផ្អើល ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ ដែលឆ្លងកាត់ការប៉ុនប៉ងនឹងបង្ខំឲ្យរៀបការ ហើយ៤៥.៧%និយាយថា ខ្លួនមិនហ៊ានប្រកែកមិនព្រមតាមគេនោះទេ(គ្មានទិន្នន័យបង្ហាញ)។

ដូចគ្នាដែរ ជាញឹកញាប់អ្នកផ្តល់សម្ភាសន៍រាយការណ៍អំពីការចាប់ពង្រាត់ ក្នុងគោលបំណងយកទៅសម្លាប់ចោល។ ប្រមាណា៤៤ភាគរយបានឃើញហេតុការណ៍នេះកើតឡើងចំពោះអ្នកដទៃ និងជិតមួយភាគបីបានឃើញសមាជិកក្រុមគ្រួសារខ្លួនត្រូវបានយកទៅសម្លាប់។

ភាគរយសម្រាប់អ្នកដែលបានឆ្លងកាត់ ឬបានឃើញព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្ត បើតាមការរាយការណ៍របស់អ្នកផ្តល់សម្ភាសន៍ មានដូចបង្ហាញក្នុងតារាងខាងក្រោម។

**Figure 1: Traumatic Events (experienced and witnessed) as reported by the participants**



## *ឥរិយាបទចំពោះអតីតខ្មែរក្រហម*

លទ្ធផលបង្ហាញខាងលើផ្ដល់នូវរូបភាពមួយនៃការឈឺចាប់ដែលបានអូសបន្លាយដ៏ធ្ងន់ធ្ងរក្នុងចំណោមអ្នកចូលរួមផ្ដល់សម្ភាសន៍ភាគច្រើន។ អាចសន្មតបានថា វានៅតែប៉ះពាល់ដល់ការយល់ឃើញរបស់ពួកគាត់ចំពោះអតីតខ្មែរក្រហម និងការពេញចិត្តផ្សះផ្សា អភ័យទោស ឬសងសឹកវិញ។ ត្រង់នេះគួរបង្គុលបង្ហាញផងដែរថា នៅកម្ពុជា ជនរងគ្រោះ និងជនដៃដល់ជាច្រើនកំពុងរស់នៅលាយឡំគ្នានៅក្នុងភូមិតែមួយ។

ប្រសិនបើសួរថាអ្នកចូលរួមផ្ដល់សម្ភាសន៍នៅតែយល់ឃើញថាអាចមានជម្លោះរវាងអតីតខ្មែរក្រហម និងអ្នកមិនមែនខ្មែរក្រហមឬអត់នោះ ភាគច្រើនបដិសេធថាគ្មានករណីបែបនេះឡើយ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៩២.១ភាគរយតបថា “ទេ” និងអ្នកមិនដាក់ពាក្យមាន ៩០%នៃករណី (គ្មានទិន្នន័យបង្ហាញ)។

ភាគច្រើននៃអ្នកចូលរួមផ្ដល់ចម្លើយបានថ្លែងថា ខ្លួនលែងខ្លាចខ្មែរក្រហមទៀតហើយ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញអំពីកម្រិតខ្ពស់ជាងបន្តិចបន្តួចនៃការភ័យខ្លាច ដែលនៅតែមាននៅឡើយ។

**Figure 2: Fear of the former Khmer Rouge as perceived by the respondents**

**តើអ្នកនៅមានអារម្មណ៍ខ្លាចពួកអតីតខ្មែរក្រហមដែរឬទេ (%)**




ជិតមួយភាគប្រាំនៃអ្នកចូលរួមផ្ដល់សម្ភាសន៍ឯកភាព “ទាំងស្រុង” នៅពេលសួរពួកគេអំពីការមានអារម្មណ៍ចង់សងសឹក ហើយមួយភាគប្រាំទៀតអះអាងថា ពួកគេមានអារម្មណ៍ចង់សងសឹកនឹងពួកខ្មែរក្រហម ក្នុង “ទ្រង់ទ្រាយដ៏ធំធេងមួយ”។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញនូវអារម្មណ៍ខ្លាំងជាងនេះច្រើនក្នុងការចង់សងសឹក បើប្រៀបធៀបទៅនឹងអ្នកដែលមិនបានដាក់ពាក្យនៅអវតក។ អារម្មណ៍នេះត្រូវបានគាំទ្រដោយរបកគំហើញរបស់ Field និង ឈឹម [58] ដែលអាចបង្ហាញថា ជនរងគ្រោះ ដែលចាប់អារម្មណ៍ចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ មានអារម្មណ៍ខ្លាំងជាងក្នុងការសងសឹកនឹងជនដៃដល់។

[58] Field, N. & Chhim, S. (2008). ការចង់សងសឹក និងឥរិយាបទចំពោះតុលាការខ្មែរក្រហម ក្នុងចំណោមជនជាតិកម្ពុជា។ *J Loss Trauma*. 13(4), 352-372.

**Figure 3: អារម្មណ៍ចង់សងសឹកបង្ហាញដោយអ្នកចូល**

**តើអ្នកមានអារម្មណ៍ចង់សងសឹកនឹងពួកអតីតខ្មែរក្រហមដែរឬទេ (%)**




ស្របគ្នានឹងរបកគំហើញខាងលើដែរ ស្ទើរតែពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍ប្រាប់ថា ខ្លួន "មិនអាច" អភ័យទោសឲ្យពួកខ្មែរក្រហមបានឡើយ ខណៈដែលមានតែ១៦%ប៉ុណ្ណោះបង្ហាញថា ខ្លួនបានអភ័យទោស "ក្នុងទ្រង់ទ្រាយធំផេងមួយ" ឬ អភ័យទោសឲ្យ "ទាំងស្រុង"។ ជាមធ្យម អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថាខ្លួន មិនទាន់បានត្រៀមខ្លួនអភ័យទោសឲ្យអតីតខ្មែរក្រហមនៅឡើយ ហើយមានតែ១.២%ប៉ុណ្ណោះ (៣នាក់ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍២៨៧នាក់)ឆ្លើយថា ខ្លួនបានអភ័យទោសឲ្យពួកខ្មែរក្រហម "ទាំងស្រុង" រួចហើយ។

**Figure 4: Forgiveness as expressed by the respondents**

**តើអ្នកអាចអភ័យទោសឲ្យពួកអតីតខ្មែរក្រហមបានហើយឬនៅ (%)**




យើងខ្ញុំទទួលបានរបកគំហើញដូចគ្នានេះដែរ នៅពេលដែលសួរអ្នកផ្តល់សម្ភាសន៍អំពីការត្រៀមខ្លួនរបស់ពួកគេចំពោះការផ្សះផ្សា។ ប្រមាណពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍ថ្លែងថា ខ្លួននៅ

“មិនទាន់” បានត្រៀមខ្លួននៅឡើយ និងច្រើនជាងមួយភាគប្រាំនិយាយថា ខ្លួន “ជាផ្នែកខ្លះ” បានត្រៀមខ្លួនផ្សះផ្សាជាមួយនឹងអតីតពួកខ្មែរក្រហម ខណៈដែលមានតែ១៣ភាគរយប៉ុណ្ណោះបានត្រៀមខ្លួន ក្នុង “ទ្រង់ទ្រាយធំដុំ” និង៣ភាគរយបានត្រៀមខ្លួន “ទាំងស្រុង” ក្នុងការផ្សះផ្សា។

គំនូសខាងក្រោមបង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទំនងជាមិនទាន់បានត្រៀមខ្លួននៅកម្រិតទាបជាងនេះទៀត ក្នុងការផ្សះផ្សា ដែលវាមិនគួរឲ្យភ្ញាក់ផ្អើលអ្វីឡើយ ត្បិតពួកគេមាននិន្នាការខ្លាំងជាងក្នុងការចង់សងសឹក និងមានកម្រិតនៃការអភ័យទោសឲ្យទាបជាង។

**Figure 5: Readiness to reconcile as expressed by the respondents**

**តើអ្នកបានត្រៀមខ្លួនហើយឬនៅក្នុងការផ្សះផ្សាជាមួយនឹងពួកអតីតខ្មែរក្រហម(%)**




ដោយមានការត្រៀមចិត្តនៅកម្រិតទាបចំពោះការផ្សះផ្សានោះ វាអាចនឹងនាំឲ្យការសាកសួរអំពីអ្វីដែលពិតជាបានកើតឡើងក្នុងបរិបទនេះ ក្នុងអំឡុងពេល៣០ឆ្នាំកន្លងទៅនេះ។ ច្រើនជាងពីរភាគបីនៃអ្នកផ្តល់សម្ភាសន៍បានអះអាងថា គ្មានការផ្សះផ្សា “អ្វីទាំងអស់” រវាងពួកខ្មែរក្រហម និង អ្នកមិនមែនជាពួកខ្មែរក្រហមនៅតាមមូលដ្ឋាន។ គួរឲ្យកត់សម្គាល់ផងដែរថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីគ្មានអ្វីដែលខុសគ្នាធំដុំឡើយក្នុងការវាយតម្លៃរបស់ពួកគេអំពីដំណើរការផ្សះផ្សាមុននេះ។

**តើអ្នកគិតថា មានការផ្សះផ្សាកើតឡើងក្នុងភូមិអ្នកដែរឬទេ? (%)**




រហូតមកដល់ចំណុចនេះ លទ្ធផលបង្ហាញនូវកង្វះខាតនៃការយល់ដឹងអំពីដំណើរការផ្សះផ្សាក្នុងសហគមន៍ រួមជាមួយនឹងកម្រិតទាបនៃការត្រៀមខ្លួនក្នុងការផ្សះផ្សា និងអារម្មណ៍ចង់សងសឹកពិសេសក្នុងចំណោមអនុក្រុមនៃប៉ាន់គំរូរបស់យើងខ្ញុំ ដែលពួកគេជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

*ឥរិយាបទចំពោះអវតក*

ដោយពិចារណាទៅលើរបកគំហើញដូចបានរៀបរាប់ខាងលើ ហាក់ដូចជាមានតម្រូវការនៃវិធានការ ដើម្បីលើកកម្ពស់ការផ្សះផ្សាក្នុងសង្គមកម្ពុជា។ អវតកត្រូវបានបង្កើតឡើង មិនត្រឹមតែ ដើម្បីផ្តល់នូវយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីរួមចំណែកដល់ការផ្សះផ្សាក្នុងសង្គមកម្ពុជាផងដែរ។

នៅពេលសាកសួរអ្នកផ្តល់បទសម្ភាសន៍ ថាតើពួកគេគិតថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សានៅកម្ពុជាឬអត់នោះ ជាងពាក់កណ្តាលបានឯកភាព និងមួយភាគបីរំពឹងថា អវតកនឹងរួមចំណែក យ៉ាងហោចណាស់ "មួយចំណែក" ក្នុងការផ្សះផ្សា។ ដូច្នេះ ចម្លើយនៃអ្នកផ្តល់សម្ភាសន៍ប្រមាណបួនក្នុងចំណោមប្រាំនាក់បង្ហាញថា មានការរំពឹងទុកថា អវតកនឹងសម្របសម្រួលការផ្សះផ្សានៅកម្ពុជា។

**Figure 7: Contribution to reconciliation by the ECCC as assessed by respondents**

**តើអ្នកគិតថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សានៅកម្ពុជាដែរឬទេ? (%)**




ការផ្សព្វផ្សាយព័ត៌មាន សកម្មភាពផ្សព្វផ្សាយ និងការជ្រើសរើសសាក្សី ក៏ដូចជា អ្នកចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ជាការងារដ៏សំខាន់ក្នុងចំណោមការងារនានារបស់អវតក ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកទាំងនេះ។ ដូច្នេះ វាសំខាន់ក្នុងផ្តល់ដំណឹងដល់ប្រជាជនអំពីអត្ថិភាពរបស់តុលាការ។ ដូចបានរៀបរាប់ខាងលើ ការជូនដំណឹងដល់ជនរងគ្រោះអំពីអវតក ជាជំហានដំបូងគេបង្អស់ក្នុងការងារផ្សព្វផ្សាយរបស់អង្គការមិនមែនរដ្ឋាភិបាល។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ (៨៧៣នាក់) ដែលមិនត្រូវបានទំនាក់ទំនងតាមរយៈអង្គការមួយដែលធ្វើកម្មវិធីផ្សព្វផ្សាយ ៨៤.៧ភាគរយនិយាយថា ពួកគេដឹងអំពីអត្ថិភាពរបស់តុលាការខ្មែរក្រហម។ ១៥.៣ភាគរយទៀតមិនដែលបានដឹងឮអំពីអវតកសោះ មុនពួកគេផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះ (គ្មានទិន្នន័យបង្ហាញ)។

អ្នកផ្តល់សម្ភាសន៍ក៏ត្រូវបានសាកសួរថាតើពួកគេកោតសរសើរចំពោះតុលាការខ្មែរក្រហមឬអត់។ ភាគច្រើនបានឯកភាព ក្នុងនោះ៩២.១ភាគរយបានឆ្លើយថា “បាទ” និង២.៨ឆ្លើយឯកភាព ប៉ុន្តែបន្ថែមទៀតថា វាចំណាយពេលអស់យូរខ្លាំងពេក ទំរាំតែតុលាការនេះត្រូវបានបង្កើតឡើង (គ្មានទិន្នន័យបង្ហាញ)។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានសាកសួរក្នុងសំណួរបើកចំហមួយផងដែរអំពីមូលហេតុ ដែលពួកគេបានសម្រេចចិត្តដោយខ្លួនឯង ក្នុងការដាក់ពាក្យ។ ស្វែងរកយុត្តិធម៌ ជាចម្លើយ ដែលយើងខ្ញុំជួបប្រទះញឹកញាប់ជាងគេបង្អស់ បន្ទាប់មក ការចង់សងសឹក ជាមូលហេតុមួយដែលបណ្តាលឲ្យអ្នកដាក់ពាក្យមួយភាគបីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ រីឯចម្លើយពាក់ព័ន្ធនឹងសំណង និងអារម្មណ៍ជាប់កាតព្វកិច្ចត្រូវធ្វើចំពោះសាច់ញាតិមិនសូវបានឮញឹកញាប់ប៉ុន្មានឡើយ។ គំនូសទី៨បង្ហាញតែប្រាំមួយមូលហេតុ ដែលឮញឹកញាប់ជាងគេប៉ុណ្ណោះ។

**Figure 8: Reasons for the application as a Civil Party**

**ហេតុអ្វីបានជាអ្នកសម្រេចចិត្តដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី?(%នៃករណី)**




*ឥរិយាបទចំពោះសំណង*[59]

សំណងសម្រាប់ជនរងគ្រោះត្រូវបានចាត់ទុកជារឿងសំខាន់ ដោយអ្នកផ្ដល់សម្ភាសន៍ភាគច្រើន។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាមទារសំណងនេះយ៉ាងទទូច និងញឹកញាប់ជាងបើប្រៀបធៀបទៅនឹងអ្នកមិនបានដាក់ពាក្យ។

នៅពេលសួរថា នរណាគួរផ្ដល់សំណង ប៉ុន្តែ៦០%និយាយថា  ជនដៃដល់គួរចេញលុយផ្ដល់សំណងទាំងអស់។ ប្រមាណពាក់កណ្ដាលនៃអ្នកផ្ដល់សម្ភាសន៍ចង្អុលបង្ហាញថា សំណងទាំងនេះគួរត្រូវបានផ្ដល់ឲ្យសហគមន៍ ប៉ុន្តែច្រើនជាងមួយភាគបីឆ្លើយថា សំណងគួរជាសំណងជាលក្ខណៈបុគ្គល។

ភាគច្រើននៃអ្នកផ្ដល់សម្ភាសន៍ចង់បានសំណងថវិកាជាលក្ខណៈបុគ្គល។ សំណងសមូហភាព ដូចជា សេវាកម្មសង្គម ឬកសាងហេដ្ឋារចនាសម្ព័ន្ធត្រូវបានទាមទារតិចជាង។ មានតែអ្នកផ្ដល់សម្ភាសន៍មួយចំនួនតូចប៉ុណ្ណោះចង់បានសំណង ដែលស្ថិតក្នុងប្រភេទសំណងផ្លូវចិត្ត ដូចជា ការរៀបចំបុណ្យទានឲ្យជនរងគ្រោះ ឬការសុំទោសពីជនដៃដល់។ យ៉ាងណាមិញ បុណ្យទានដែលត្រូវបានទាមទារដ៏គួរឲ្យកត់សម្គាល់ញឹកញាប់ជាង ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បើប្រៀបធៀបទៅនឹងជនរងគ្រោះទូទៅ ដែលមិនបានចូលរួមក្នុងនីតិវិធីរបស់អវតក។

[59] លទ្ធផលត្រូវបានបោះពុម្ពផ្សាយរួចហើយក្នុង: Stammel, N., Bockers, E., Taing, S. & Knaevelsrud, C. (2010)។ តម្រូវការអ្នកនៅរស់រានមានជីវិត ◌: មតិយោបល់ស្ដីពីសំណងសម្រាប់ជនរងគ្រោះពីរបបខ្មែរក្រហមនៅកម្ពុជា។ *Traumatic Stress Points*, 24 (6), 7-9.

**តារាង៣០: មតិយោបល់របស់អ្នកផ្តល់សម្ភាសន៍អំពីសំណង**

| | | Total | No CPA | CPA |
|---|---|---|---|---|
| តើវាសំខាន់ទេ ក្នុងការផ្តល់សំណងឲ្យជនរងគ្រោះពីរបបខ្មែរក្រហម? (% បាទ/ចាស) | | 80.0 | 78.0 | 86.6 |
| តើសំណងគួរផ្តល់ឲ្យបុគ្គល ឬសហគមន៍ ឬទាំងពីរ? | បុគ្គល (%) | 35.3 | 34.1 | 38.9 |
| | សហគមន៍ (%) | 51.2 | 53.2 | 45.2 |
| | ទាំងពីរ (%) | 13.5 | 12.7 | 15.9 |
| តើនរណាគួរចំណាយទៅលើសំណងដែលត្រូវផ្តល់ឲ្យជនរងគ្រោះ? | ជនដៃដល់ (%) | 60.8 | 60.8 | 60.6 |
| | សហគមន៍ (%) | 1.2 | 1.5 | - |
| | រដ្ឋាភិបាល (%) | 20.8 | 22.9 | 14.4 |
| | សហគមន៍អន្តរជាតិ (%) | 11.0 | 8.9 | 17.4 |
| | ផ្សេងៗ (%) | 6.3 | 5.8 | 7.6 |

CPA = អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**តារាង៤០: ប្រភេទនៃសំណងស្នើឡើងដោយអ្នកផ្តល់សម្ភាសន៍**

| | សរុប (%) | No CPA (%) | CPA (%) |
|---|---|---|---|
| សំណងថវិកាជាលក្ខណៈបុគ្គល | 36.8 | 39.1 | 30.3 |
| សេវាកម្មសង្គម (សេវាសុខភាព អប់រំ...) | 15.2 | 13.7 | 19.5 |
| បុណ្យទានសម្រាប់អ្នកស្លាប់ និងជនរងគ្រោះដែលនៅរស់ | 9.2 | 6.7 | 16.0 |
| ហេដ្ឋារចនាសម្ព័ន្ធ | 9.1 | 8.4 | 11.3 |
| ផ្ទះ និង ដី | 8.5 | 9.2 | 6.5 |
| ការអភិវឌ្ឍសេដ្ឋកិច្ច និងកម្មវិធីលើកកំពស់ពាណិជ្ជកម្ម | 6.9 | 7.5 | 5.2 |
| សត្វពាហន: ម្ហូបអាហារ គ្រឿងបរិក្ខារកសិកម្ម | 3.7 | 4.1 | 2.6 |
| រូបសំណាក សារមន្ទីរ បូជនីយដ្ឋាន | 3.1 | 2.8 | 4.3 |

| | | | |
|---|---|---|---|
| ការសុំទោសពីជនដៃដល់ | 2.9 | 3.7 | 0.9 |
| វត្តអារ៉ាម និង ព្រះវិហារ (អុិស្លាម) | 1.5 | 1.4 | 1.7 |
| យុត្តិធម៌ | 0.8 | 1.1 | - |
| ថ្ងៃរំលឹក និង កំណត់ត្រាក្នុងប្រវត្តិសាស្ត្រ | 0.3 | 0.2 | 0.4 |
| ផ្សេងៗ | 1.9 | 2.1 | 1.3 |

CPA = អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

## ៣.៤ ចំនុចខ្វះខាត

មានចំនុចខ្វះខាតមួយចំនួនក្នុងលទ្ធផលនៃការអង្កេតនេះ ដែលចាំបាច់ត្រូវតែចង្អុលបង្ហាញ។

ដំបូង នីតិវិធីនៃការជ្រើសរើសប៉ាន់គំរូមិនបានអនុវត្តទៅតាមវិធីសាស្ត្រជ្រើសរើសដោយចៃដន្យឡើយ ដូច្នេះហើយរបកគំហើញអាចមិនបង្ហាញអំពីភាពទូទៅចំពោះប្រជាជនកម្ពុជា។ បន្ថែមលើនេះទៀត ដោយអ្នកផ្តល់សម្ភាសន៍ត្រូវបានជ្រើសរើស តាមរយៈការសាកសួរអ្នកភូមិឲ្យចូលរួមផ្តល់បទសម្ភាសន៍ ដូច្នេះវាមានករណីដែលថា អ្នកនៅរស់រានមានជីវិតដែលរួមបញ្ចូលក្នុងប៉ាន់គំរូ គឺគ្រាន់តែជា អ្នកដែលចាប់អារម្មណ៍លើប្រធានបទ ហើយមានអារម្មណ៍បានត្រៀមខ្លួននិយាយអំពីរឿងរ៉ាវរបស់ខ្លួន។

បញ្ហាមួយទៀតកើតឡើង នៅពេលដែលមតិយោបល់ និងខ្លឹមសារត្រូវបានបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរ។ ទាំងពីរភាសាខុសពីគ្នាត្រង់ចំណុចមួយចំនួន។ ដើម្បីដោះស្រាយបញ្ហានេះ ដំណើរការពិភាក្សា និងបកប្រែភាសាដ៏ទូលំទូលាយមួយត្រូវបានអនុវត្ត ក្នុងគោលបំណងពិនិត្យសម្រេចតារាងសំណួរ ក្នុងនោះរួមមាន ការបកប្រែត្រឡប់មកជាភាសាអង់គ្លេសវិញ ហើយការពិភាក្សាពិស្តារមួយជាមួយអ្នកជំនាញក្នុងស្រុកអំពីអត្ថន័យពាក្យពេចន៍ដែលប្រើប្រាស់ក្នុងការអង្កេតនេះ។

ដោយអំឡុងពេលធ្វើសម្ភាសន៍នៅចន្លោះពីខែតុលា ឆ្នាំ២០០៨ ដល់ ខែឧសភា ឆ្នាំ២០០៩ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលចូលរួមក្នុងការអង្កេតនេះគឺស្ថិតក្នុងចំណោមអ្នកនៅរស់រានមានជីវិតដំបូងៗគេនៅកម្ពុជា ដែលមានឱកាសដាក់ពាក្យនៅអវតក។ នីតិវិធីទាំងមូល ក៏ដូចជាសកម្មភាពផ្សព្វផ្សាយអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនានានៅថ្មីថ្មោង និងកំពុងអភិវឌ្ឍបន្ថែមលើបទពិសោធន៍ដំបូងៗនៅឡើយ។ ដូច្នេះ ទិន្នន័យនៅក្នុងការអង្កេតនេះអាចមិនតំណាងឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ពាក្យបន្ទាប់មក និងបានទទួលនូវកម្មវិធីផ្សព្វផ្សាយដែលត្រូវបានកែសម្រួល។

ទីបញ្ចប់ ដំណើរការនីតិវិធីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច បានចាប់ផ្តើម ក្នុងអំឡុងពេលនៃការប្រមូលទិន្នន័យ គឺថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩។ វាអាចមានករណីដែលថា អ្នកផ្តល់សម្ភាសន៍ ដែលបានជូនដំណឹងអំពីការជំនុំជម្រះ អាចទទួលឥទ្ធិពលលើឥរិយាបទរបស់ពួកគេចំពោះអវតក និងចំពោះអតីតជនដៃដល់ពីព្រឹត្តិការណ៍នេះ។

# ៩. ការសិក្សាជាមួយអ្នកដាក់ពាក្យ (២០១០)

## ៩.១ វិធីសាស្ត្រ

*របាយជ្រើសរើសប៉ាន់គំរូ*

ចំនួនសរុបនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី២២៦នាក់ត្រូវបានសម្ភាសនៅក្នុងខេត្ត-ក្រុងនៃប្រទេសកម្ពុជា ដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ពួកគេខ្លះបានទទួលដំណឹងអំពីការបដិសេធ ឬការទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅអវតក។ ដូចមានពណ៌នាក្នុងជំពូក៣ អ្នកផ្តល់សម្ភាសន៍ទាំងអស់ក្នុងការអង្កេតនេះស្ថិតក្នុងចំណោមជនរងគ្រោះដំបូងៗគេបង្អស់ ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអវតក។

**តារាង៥០:**
**អ្នកផ្តល់សម្ភាសន៍តាមខេត្តនីមួយៗ (%)**

| | |
|---|---|
| កំពត | 24.3 |
| ស្វាយរៀង | 17.7 |
| កំពង់ស្ពឺ | 10.6 |
| ស្ទឹងត្រែង | 8.4 |
| កំពង់ចាម | 7.1 |
| តាកែវ | 6.6 |
| កោះកុង | 5.8 |
| ព្រះសីហានុ | 4.9 |
| រតនគិរី | 3.5 |
| កំពង់ឆ្នាំង | 3.5 |
| ក្រចេះ | 2.7 |
| ភ្នំពេញ | 1.8 |
| កណ្តាល | 1.3 |
| ប៉ៃលិន | 1.3 |
| សៀមរាប | 0.4 |

*អ្នកធ្វើសម្ភាសន៍*

បទសម្ភាសន៍ត្រូវបានធ្វើឡើងដោយអ្នកធ្វើសម្ភាសន៍ជំនាញចិត្តវិទ្យាជនជាតិកម្ពុជា។ ពាក់កណ្តាលនៃពួកគេបានចូលរួមក្នុងការអង្កេតឆ្នាំ២០០៨/២០០៩ម្តងរួចហើយ។ អ្នកធ្វើសម្ភាសន៍ត្រូវបានបណ្តុះបណ្តាលក្នុងសិក្ខាសាលាមួយរយៈពេលពីរសប្តាហ៍។ ទស្សនាទានផ្លូវចិត្តពាក់ព័ន្ធនឹងសង្គ្រាម ការប៉ះទង្គិចផ្លូវចិត្ត និងផលវិបាកសុខភាពផ្លូវចិត្ត ត្រូវបានយកមកណែនាំ។ ខ្លឹមសារ និងទស្សនាទាននៃតារាងសំណួរត្រូវបានយកមកពិភាក្សា និងកែតម្រូវ នៅពេលចាំបាច់។ ក្នុងវគ្គបណ្តុះបណ្តាលជាក់ស្តែងអ្នកធ្វើសម្ភាសន៍ត្រូវបានបង្រៀនអំពីរបៀបប្រើប្រាស់តារាងសំណួរ។

*នីតិវិធី*

អ្នកផ្តល់សម្ភាសន៍ទាំងអស់ ដែលចូលរួមក្នុងការអង្កេតទីពីរនេះ ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្ភាសម្តងរួចហើយក្នុងឆ្នាំ២០០៨ ឬ២០០៩។ ពួកគេត្រូវបានទំនាក់ទំនងម្តងទៀត ក្នុងបំណងស្នើសុំឲ្យចូលរួមក្នុងការអង្កេតទីពីរនេះទៀត។

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ក្នុងការអង្កេតលើកទីមួយ ១២នាក់មិនត្រូវបានរកឃើញជាថ្មីឡើយ ៥នាក់បដិសេធមិនចូលរួម ខណៈដែលបទសម្ភាសន៍ចំនួនពីរមិនត្រូវធ្វើឡើយដោយសារតែបញ្ហាសុខភាពពាក់ព័ន្ធនឹងអាយុ។ គួរឲ្យស្តាយទៀតនោះ អតីតអ្នកផ្តល់សម្ភាសន៍ពីរនាក់បានទទួលមរណភាពក្នុងរយៈពេលនៃការធ្វើសម្ភាសន៍។ ជាសរុប ចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី២៤៧ដែលបានផ្តល់សម្ភាសន៍ក្នុងការអង្កេតមុន ២២៦នាក់បានផ្តល់សម្ភាសន៍ជាថ្មីម្តងទៀតក្នុងការអង្កេតលើកទីពីរ។

អ្នកផ្តល់សម្ភាសន៍ត្រូវបានសម្ភាសជាលក្ខណៈជួបមុខផ្ទាល់ ដោយប្រើប្រាស់ភាសាខ្មែរ នៅចន្លោះថ្ងៃទី២ ខែតុលា ឆ្នាំ២០១០ និងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០។

មុននឹងធ្វើសម្ភាសន៍នីមួយៗ អ្នកផ្តល់សម្ភាសន៍ត្រូវបានផ្តល់ព័ត៌មានអំពីចំណុចខាងក្រោម និងត្រូវផ្តល់ការព្រមព្រៀងផ្ទាល់មាត់៖

- លក្ខណៈស្ម័គ្រចិត្តទាំងស្រុងនៃបទសម្ភាសន៍
- រយៈពេល និងប្រធានបទនៃបទសម្ភាសន៍
- សិទ្ធិក្នុងការបដិសេធមិនឆ្លើយសំណួរណាមួយ ក៏ដូចជា សិទ្ធិក្នុងការបញ្ចប់បទសម្ភាសន៍ក្នុងពេលណាក៏បាន
- គោលការណ៍នៃការរក្សាការសម្ងាត់ និងអនាមិកភាព

នៅចុងបញ្ចប់បទសម្ភាសន៍នីមួយៗ អ្នកផ្តល់សម្ភាសន៍ទទួលបានកាដូដ៏តូចមួយ គឺមុងមួយ។ ជាមធ្យម បទសម្ភាសន៍នីមួយៗត្រូវការរយៈពេល១ម៉ោង កន្លះ។

## ៤.២ ខ្នាតវាស់វែង

ខ្នាតវាស់វែងដូចមានបង្ហាញនេះ ត្រូវបានបង្កើតក្នុងក្រុមការងាររបស់ bzfo ដោយមានកិច្ចសហការជាមួយអង្គការធីភីអូ កម្ពុជា។ ខ្នាតវាស់វែងមួយចំនួនត្រូវបានយកចេញពីការអង្កេតទីមួយ។ អថេរសាកល្បងមួយចំនួន (ការពេញចិត្តនឹងប្រយោគ ប្រតិកម្មផ្នែកអារម្មណ៍ទៅនឹងសេចក្ដីសម្រេចរបស់តុលាការ ផលប៉ះពាល់របស់ការសាកល្បងលើជីវិតរបស់អ្នកផ្ដល់សម្ភាសន៍) ជាការកែសម្រួលតារាងសំណួរ ដែលដើមឡើងបង្កើតឡើងដោយ Orth & Maercker[60] ។ សំណួរបួនស្ដីពីការយល់ឃើញចំពោះការសុំអភ័យទោសរបស់ឌុច និងការលើកលែងទោស ត្រូវបានយកចេញពីសំណួរ ដែលដើមឡើងបង្កើតឡើងដោយ Allan និងសហការី[61] ។ គ្រប់សំណួរទាំងអស់ត្រូវបានសម្របទៅតាមបរិបទកម្ពុជា។

សំណួរថ្មីៗទាំងអស់ត្រូវបានបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ដោយអ្នកចិត្តវិទ្យាកម្ពុជា និងបកប្រែត្រឡប់ទៅជាភាសាអង់គ្លេសវិញ ដោយអ្នកបកប្រែ ដែលមិនបានយល់/ឃើញសំណៅដើម ជាភាសាអង់គ្លេស ដើម្បីផ្ទៀងផ្ទាត់អំពីគុណភាពនៃការបកប្រែ ដើម្បីឲ្យស្របគ្នាទៅនឹងខ្លឹមសារដើម។

## ៤.៣ លទ្ធផល

*ការបង្ហាញ និងការវិភាគទិន្នន័យ*

ទិន្នន័យត្រូវបានវិភាគ ដោយប្រើប្រាស់កម្មវិធី Statistical Package for Social Sciences (SPSS) កំណែ ១៧.០។ ជាទូទៅ របកគំហើញនានាត្រូវបានបង្ហាញជាក្រុមទាំងមូលនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន២២៦នាក់។

សំណួរខ្លះអនុញ្ញាតឲ្យមានចម្លើយតបច្រើន (គូសបញ្ជាក់ក្រោមចំណងជើងថា ចំនួនជា "%នៃករណី") ដូច្នេះក្រាហ្វិកបង្ហាញអំពីភាគរយនៃអ្នកដែលបានផ្ដល់ចម្លើយនីមួយ។

ប្រសិនបើសំណួរនោះត្រូវបានសួរក្នុងការអង្កេតទាំងពីរនោះ ការប្រៀបធៀបវាយតម្លៃរវាងការអង្កេតលើកទីមួយ (២០០៨/២០០៩) និងការអង្កេតលើកទីពីរ (២០១០) ត្រូវបានបង្ហាញ។

[60] Orth, U. & Maercker, A. (2004). តើការជំនុំជម្រះជនល្មើសធ្វើឲ្យជនរងគ្រោះពីឧក្រិដ្ឋកម្មទទួលនូវការប៉ះទង្គិចផ្លូវចិត្តជាថ្មីម្ដងទៀតឬ? *Journal of Interpersonal Violence*, 19(2), 212-227.

[61] Allan, A., Allan, M.M., Kaminer, D. & Stein, D.J. (2006). ការស្វែងយល់អំពីទំនាក់ទំនងរវាងការសុំទោស និងការអភ័យទោសឲ្យក្នុងចំណោមជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស *Behavioral Sciences and the Law*, 24, 87-102

*ប្រជាសាស្ត្រសង្គម*

ចំនួនសរុបនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី២២៦នាក់ក្នុងការអង្កេតនេះត្រូវបានបង្ហាញពីការអង្កេតលើកទីមួយក្នុងឆ្នាំ២០០៨/២០០៩។ ជាមធ្យម អ្នកផ្ដល់សម្ភាសន៍ចាស់ជាងមុន ១.៧ ឆ្នាំ។

**តារាង៦ : ប្រជាសាស្ត្រសង្គម**

| **ទំហំប៉ាន់គំរូ (n)** | **% ស្ត្រី** | **អាយុមធ្យម អាយុ (S.D.)** | **ស្ថានភាពគ្រួសារ** | | | | |
|---|---|---|---|---|---|---|---|
| | | | រៀបការ | មេម៉ាយ | លែងលះ | នៅលីវ | ផ្សេងៗ |
| 226 | 70.4% | 58.5 (9.7) | 56.2 | 36.7 | 2.2 | 2.7 | 2.2 |

| **ល្បាយអាយុ (%)** | | | | **ការអប់រំ** | | | |
|---|---|---|---|---|---|---|---|
| 35-44 ឆ្នាំ | 45-54 ឆ្នាំ | 55-64 ឆ្នាំ | > 65 ឆ្នាំ | ការអប់រំមធ្យមគិតជាឆ្នាំ (S.D.) | អក្ខរកម្ម (%) | | |
| | | | | | បាទ | តិចតួច | ទេ |
| 8.0 | 27.1 | 36.9 | 28.0 | 3.8 (3.8) | 40.4 | 24.4 | 35.1 |

| **ជនជាតិដើមភាគតិច (%)** | | | | **ជំនឿសាសនា (%)** | | | |
|---|---|---|---|---|---|---|---|
| ខ្មែរ | ចាម | ចិន | ផ្សេងៗ | ព្រះពុទ្ធ | អុីស្លាម | គ្រីស្ទ | ផ្សេងៗ |
| 77.9 | 13.3 | 0.9 | 8.8 | 79.2 | 18.1 | 2.2 | 0.4 |

*ប្រតិកម្ម និងផលប៉ះពាល់លើក្រុមគ្រួសាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

អ្នកផ្តល់សម្ភាសន៍ទាំងអស់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មុនការអង្កេតលើកទីមួយក្នុងឆ្នាំ២០០៨/២០០៩។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងប៉ាន់គំរូនេះនិយាយថា ក្នុងចំណោមជាង៧៥ភាគរយនៃករណីទាំងអស់ សមាជិកក្រុមគ្រួសាជិតៗរបស់ខ្លួនទាំងអស់ដឹងអំពីការដាក់ពាក្យរបស់ខ្លួន។ តែ៥ភាគរយប៉ុណ្ណោះ ដែលមិនបានប្រាប់នរណាសោះក្នុងគ្រួសាររបស់ខ្លួន។

**Figure 9: Family members' knowledge about the application as indicated by the participants**
**Do your immediate family members know that you applied to become a civil party to the ECCC? (%)**




**Figure 10: Family members' reaction towards the application as indicated by the participants**
**តើពួកគេមានប្រតិកម្មយ៉ាងម៉េចនៅពេលដែលពួកគេឮថាអ្នកបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអវតក? (%)**




ក្នុងចំណោមអ្នកដែលបានប្រាប់ក្រុមគ្រួសារខ្លួន (សរុប២១៨នាក់) តិចតួចណាស់បានទទួលប្រតិកម្មអវិជ្ជមានពីសមាជិកក្រុមគ្រួសាររបស់ខ្លួន នៅពេលពួកគេបានប្រាប់ពីការដាក់ពាក្យ។ ច្រើនជាង

ពាក់កណ្តាលនិយាយថា បានទទួលប្រតិកម្មវិជ្ជមាន ហើយចំពោះករណីផ្សេងទៀតថា ប្រតិកម្មវិជ្ជមានក៏មិនបានទទួល ចំណែកអវិជ្ជមានក៏មិនបានទទួល។ បន្ថែមលើនេះទៀត សមាជិកក្រុមគ្រួសារហាក់ដូចជា ប្រភពនៃការគាំទ្រផ្នែកសង្គម និងការលើកទឹកចិត្តដ៏សំខាន់មួយ ពាក់ព័ន្ធនឹងការដាក់ពាក្យនេះ។ ៤០ភាគរយមានអារម្មណ៍ថា ទទួលបានការគាំទ្រពីសមាជិកគ្រួសាររបស់ខ្លួន “យ៉ាងខ្លាំង” ពាក់ព័ន្ធនឹងការដាក់ពាក្យនៅអវតក។ ៣៧ភាគរយនិយាយថា ខ្លួនមានអារម្មណ៍ថា ទទួលបានការគាំទ្រ “ល្មមគួរសម” ១០ភាគរយទទួលស្គាល់ថា មានការគាំទ្រពីគ្រួសារ “តិចតួច” ឬ “អត់សោះ”។

**Figure 11: Feeling of support by family members as indicated by the participants**

**Did you feel supported by your family regarding your application as Civil Party to the ECCC? (%)**




ផលប៉ះពាល់ដែលការដាក់ពាក្យ ឬការចូលរួមរបស់អ្នកដាក់ពាក្យនៅអវតកមានលើក្រុមគ្រួសាររបស់ពួកគេជាទូទៅ គឺវិជ្ជមាន និង គ្មានប្រតិកម្មអ្វីទាំងអស់។ សរុបទៅ តែប្រាំភាគរយប៉ុណ្ណោះបង្ហាញថា មានផលប៉ះពាល់អវិជ្ជមាន។

**Figure 12: Impact of application/participation on the family as indicated by the participants**

**What impact has your application/participation at the ECCC on your family? (%)**



តំណាងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប នៅគ្រប់ពេលទាំងអស់” (ទំព័រ៣៣)[62]។ ចាប់ពីពេលដែលអ្នកដាក់ពាក្យត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីភ្លាម ពួកគេក៏ចាំបាច់ត្រូវមានមេធាវីមួយរូបដែរ។

ពួកគេក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរមុនពេលចេញដីកាដំណោះស្រាយ ដោយការជួប និងសម្ភាសកូនក្ដី និងផ្ដល់យោបល់ផ្នែកច្បាប់ ពាក់ព័ន្ធនឹងពាក្យសុំរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ លុះត្រាតែមានជំនួយពីមេធាវី ទើបការធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធអាចប្រព្រឹត្តិទៅបាន។ ក្នុងចំណោមប៉ាន់គំរូនេះ ៦១.១ភាគរយ (១៣៨នាក់)នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីស្គាល់មេធាវីរបស់ខ្លួន (គ្មានទិន្នន័យបង្ហាញ)។ លទ្ធផលខាងក្រោម ដែលមានបង្ហាញក្នុង រូបភាព ១៣ និង ១៤ សំដៅទៅលើតែអ្នកផ្ដល់សម្ភាសន៍ទាំងនេះប៉ុណ្ណោះ។

ចំពោះការទំនាក់ទំនងជាមួយមេធាវី ៨៩.១ភាគរយ គឺជាការជួបមុខផ្ទាល់ និង២០.៣ភាគរយ ជួបតាមទូរស័ព្ទ (គ្មានទិន្នន័យបង្ហាញ)។ អ្នកផ្ដល់សម្ភាសន៍ស្ទើរតែទាំងអស់ ដែលស្គាល់មេធាវីរបស់ខ្លួនបានទំនាក់ទំនងផ្ទាល់ ឬប្រយោល នៅពេលសម្ភាសន៍ យ៉ាងហោចណាស់ម្ដង។ ច្រើនជាង៦០ភាគរយ និយាយថា ពួកគេបានទំនាក់ទំនងច្រើនដងជាមួយនឹងមេធាវីខ្លួន។

**Figure 13: Frequency of lawyer consultation as reported by the respondents**

**How often did you consult your lawyer, either by phone or by direct contact? (%)**




អ្នកផ្ដល់សម្ភាសន៍ភាគច្រើន ដែលចង្អុលបង្ហាញថា ស្គាល់មេធាវីរបស់ខ្លួន មានការពេញចិត្តនឹងមេធាវីរបស់ខ្លួន។ មានតែអ្នកផ្ដល់សម្ភាសន៍ប្រាំមួយនាក់ប៉ុណ្ណោះមិនបញ្ជាក់ថា “ពេញចិត្ត ឬមិនពេញចិត្ត” ដែរ រីឯអ្នកផ្សេង យ៉ាងហោចថា “ពេញចិត្ត” បើមិនដូច្នេះទេ ថា “ពេញចិត្តខ្លាំង”។

[62] វិធាន២៣ នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទីប្រាំមួយ) ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០

**Figure 14: Satisfaction with the lawyer as reported by the respondents**

**How satisfied are you with your lawyer? (%)**




*ចំណេះដឹងអំពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

ក្នុងអំឡុងពេលនៃការធ្វើសម្ភាសន៍លើកទីពីរ ជាមធ្យមមានរយៈពេល១.៧ឆ្នាំបន្ទាប់ពីការអង្កេតលើកទីមួយ ប្រមាណពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍មិនបានដឹងថា កាលពីដើមមក ពួកគេបានដាក់ពាក្យសម្រាប់សំណុំរឿងណាមួយឡើយ។ បើពិនិត្យមើលតែអនុប៉ាន់គំរូនៃអ្នកដែលទទួលដំណឹងថា ខ្លួនជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (១១៣នាក់) ប្រមាណមួយភាគបី (២៨.៣% ) នៅតែមិនដឹងថាតើពួកគេត្រូវបានទទួលស្គាល់ ឬបដិសេធក្នុងសំណុំរឿងណាមួយឡើយ (មិនបង្ហាញទិន្នន័យ)។

បន្ទាប់ពីចេញដីកាដំណោះស្រាយសម្រាប់សំណុំរឿង០០២នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០រួចមក សេចក្តីសម្រេចដំបូងគេស្តីពីការទទួលស្គាល់ និងបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានចេញ។

យ៉ាងណាមិញ ដោយអ្នកដាក់ពាក្យដែលត្រូវបានបដិសេធមិនទទួលស្គាល់ អាចដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ ក្នុងរយៈពេលដប់ថ្ងៃ និងតាមរយៈមេធាវីរបស់ខ្លួន ដូច្នេះ ចំពោះអ្នកដែលបានប្តឹងឧទ្ធរណ៍កំពុងរង់ចាំសេចក្តីសម្រេចចុងក្រោយនៅឡើយ ក្នុងរយៈពេលនៃការធ្វើសម្ភាសន៍។

យ៉ាងណាមុិញ ពាក់កណ្តាលត្រឹមនៃអ្នកផ្តល់សម្ភាសន៍បានទទួលព័ត៌មានរួចរាល់ហើយអំពីសេចក្តីសម្រេចចុងក្រោយនៃការពាក្យសុំរបស់ខ្លួន (គ្មានទិន្នន័យបង្ហាញ)។

ប្រភពចម្បងនៃព័ត៌មាន ពាក់ព័ន្ធនឹងពាក្យសុំរបស់ពួកគេ គឺបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល (៣៧.២%) តំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រចាំតំបន់ ដែលដើរតួជាបុគ្គលសំខាន់ក្នុងបណ្តាញសហគមន៍អង្គការមិនមែនរដ្ឋាភិបាល (៣២.៧%) និងមេធាវី (២៥.៨%)។ ប្រភពផ្សេងៗទៀតមាន ៧.១ ភាគរយ ជាចម្លើយច្រើន (គ្មានទិន្នន័យបង្ហាញ)។ ជាទូទៅ អ្នកផ្តល់សម្ភាសន៍ត្រូវបានជូនដំណឹងផ្ទាល់ជា

លក្ខណៈបុគ្គល មាន៨២.៣ភាគរយ និង១៧.៧ភាគរយតាមរយៈទូរស័ព្ទ។ លិខិត ប្រើជាមធ្យោបាយនៃការជូនដំណឹងដល់អ្នកផ្តល់សម្ភាសន៍អំពីពាក្យសុំរបស់ពួកគេ មាន៧.១ភាគរយ (គ្មានទិន្នន័យបង្ហាញ)។

### *ការយល់ឃើញអំពីការជំនុំជម្រះរឿងក្តី ឌុច*

កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាជនដែលដំបូងគេ ត្រូវបានដាក់ឲ្យទទួលទោសដោយអវតក។ សវនាការជំនុំជម្រះបានចាប់ផ្តើមនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ហើយសាលក្រមត្រូវបានប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ ៧៩.២ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលរួមបញ្ចូលក្នុងការអង្កេតនេះនិយាយថា ពួកគេបានតាមដានកិច្ចដំណើរការនីតិវិធីនៅអវតក (គ្មានទិន្នន័យបង្ហាញ)។

ក្នុងចំណោមអ្នកដែលបានអះអាងថាបានតាមដានកិច្ចដំណើរការនីតិវិធី ប្រភពព័ត៌មានដែលបានឆ្លើយញឹកញាប់ជាងគេ គឺប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ពិសេស ទូរទស្សន៍ ដែលត្រូវបានប្រើប្រាស់ដោយប្រមាណពីរភាគបីនៃអ្នកផ្តល់សម្ភាសន៍ និង វិទ្យុ(៤២%)។ ប្រភពបន្ថែមទៀត រួមមាន សកម្មភាពផ្សព្វផ្សាយ ដូចជា កិច្ចប្រជុំនានា រៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងដោយមានការចូលរួមពីប្រជាពលរដ្ឋ ដូចជា ការអញ្ជើញឲ្យមកទស្សនាសវនាការផ្ទាល់នៅអវតក (១៨.៩%)។ ៤៣.១ភាគរយនៃអ្នកផ្តល់សម្ភាសន៍បានអញ្ជើញមកទស្សនាតុលាការនៅរាជធានីភ្នំពេញរួចហើយ (គ្មានទិន្នន័យបង្ហាញ)។

**Figure 15: Sources of information about the trial as indicated by the respondents**




ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ទាំងអស់ ៩១.២ភាគរយនិយាយថា ខ្លួនដឹងអំពីការដាក់ទោសឌុច (គ្មានទិន្នន័យបង្ហាញ)។ ដូច្នេះ អ្នកទាំងនេះត្រូវបានសួរអំពីចំនួនជាក់លាក់នៃឆ្នាំ ដែលឌុចត្រូវជាប់ក្នុងពន្ធនាគារ បន្ទាប់ពីការចេញសាលក្រម។

រយៈពេលជាប់ពន្ធនាគារជាផ្លូវការ ដូចបង្ហាញក្នុងសាលក្រម គឺ៣៥ឆ្នាំ បើទោះជាត្រូវព្យួរដោយហេតុផលចម្បងពីរ ដូចមានរៀបរាប់ក្នុងសេចក្តីថ្លែងការណ៍ពន្យល់បន្ថែមរបស់សាលក្រម គឺទីមួយ តុលាការបានសម្រេចព្យួររយៈពេលប្រាំឆ្នាំ ដោយឌុចត្រូវបានរក្សាទុកក្រោមការឃុំឃាំងយោធាដោយខុសច្បាប់ មុននឹងគាត់ត្រូវបានបញ្ជូនមកស្ថិតក្រោមការឃុំឃាំងរបស់អវតក។ ទីពីរ ឌុចបានជាប់ពន្ធនាគារ ១១ឆ្នាំរួចមកហើយ នៅពេលដែលការកាត់ទោសត្រូវបានសម្រេចជាចុងក្រោយ។ នេះមានន័យថា ឌុចត្រូវជាប់ពន្ធនាគាររយៈពេល១៩ឆ្នាំទៀត ដែលនេះត្រូវបានកំណត់ជាចម្លើយដ៏ត្រឹមត្រូវសម្រាប់សំណួរខាងលើ។ ក្នុងករណីដែលអ្នកផ្តល់សម្ភាសន៍ឆ្លើយថា៣៥ឆ្នាំទៀតនោះ ចម្លើយនេះត្រូវបានបកស្រាយថាជាសូចនាការមួយ បញ្ជាក់ថាពួកគេមិនដឹងអំពីចំណែកនៃការព្យួរនេះ។

ចម្លើយនៃអ្នកដែលបង្ហាញថាដឹងអំពីការដាក់ទោស (៩៣នាក់) ត្រូវបានផ្សព្វផ្សាយម្តុំ១៩ឆ្នាំ (៣៤.៤%) និង៣៥ឆ្នាំ (២៣.៣%) ដែលនេះបង្ហាញថា អ្នកផ្តល់សម្ភាសន៍មានចំណេះដឹងនៅកម្រិតជាក់លាក់មួយអំពីសាលក្រម។ ច្រើនជាង៥០%បាននិយាយថា ឌុចត្រូវបានដាក់ទោសរហូតដល់១៩ឆ្នាំ ឬ៣៥ឆ្នាំ។ ក្នុងចំណោមដែលបានអះអាងថាបានដឹងអំពីរយៈពេលជាប់ពន្ធនាគារ ប្រមាណមួយភាគបីដឹងពិតប្រាកដអំពីរយៈពេលជាប់ពន្ធនាគារត្រឹមត្រូវ គឺ១៩ឆ្នាំទៀត ដែលឌុចត្រូវនៅជាប់ពន្ធនាគារ។ យ៉ាងណាមិញ នេះបង្ហាញថា ចំនួនដ៏គួរឲ្យកត់សម្គាល់នៃអ្នកដាក់ពាក្យទទួលដំណឹងបានច្រើនអំពីសាលក្រម ប៉ុន្តែម្យ៉ាងវិញទៀត វាអាចជាសូចនាការមួយថា សាលក្រមត្រូវបានអង្កេតជាលក្ខណៈទូលំទូលាយជាង គេយល់ដឹងអំពីភាពលំអិតរបស់វា។ អ្នកផ្តល់សម្ភាសន៍បីនាក់ដែលត្រូវបានដកចេញពីតួលេខទាំងនេះ អះអាងថា ខ្លួនច្បាស់ណាស់ថា ឌុចទទួលបានការកាត់ទោសមួយជីវិត។ សម្រាប់ប៉ាន់គំរូសរុប នេះមានន័យថា ១៣.៧ភាគរយបានដឹងអំពីរយៈពេលជាប់ពន្ធនាគារត្រឹមត្រូវ (គ្មានទិន្នន័យបង្ហាញ)។

**Figure 16: Prison term of Duch according to the respondents knowledge**

**How many more years does Duch have to serve in prison? (%)**




រាល់អ្នកផ្តល់សម្ភាសន៍ ដែលបានតាមដានដំណើរការនីតិវិធី ប៉ុន្តែបង្ហាញថាខ្លួនមិនដឹងអំពីការកាត់ទោសឌុច ត្រូវបានជូនដំណឹងដោយអ្នកធ្វើសម្ភាសន៍អំពីសាលាក្រមទេ។ នេះធ្វើឡើយដោយការអានអត្ថបទដើម ដែលរួមបញ្ចូលនូវទិដ្ឋភាពដូចរៀបរាប់ខាងលើ ដែលនាំទៅរករយៈពេលជាប់

ពន្ធនាគារពិតប្រាកដ (ក្រុមដែលត្រូវបានជូនដំណឹង)។ ប្រសិនបើអ្នកផ្តល់សម្ភាសន៍គិតថា ខ្លួនដឹងអំពីរយៈពេលជាប់ពន្ធនាគារត្រឹមត្រូវ ប៉ុន្តែផ្តល់ចម្លើយមិនត្រឹមត្រូវនោះ មិនមានការផ្តល់ព័ត៌មានបន្ថែមទៀតឡើយ (ក្រុមដែលមិនត្រូវបានជូនដំណឹង)។

ជាទូទៅ ច្រើនជាង៦០ភាគរយ “ពេញចិត្ត” ឬ “ពេញចិត្តខ្លាំង” នឹងសាលក្រម ១០ភាគរយនិយាយថា “ពេញចិត្តផង និងមិនពេញចិត្តផង” ខណៈដែលប្រមាណម្នាក់ក្នុងចំណោមបួននាក់ “មិនពេញចិត្ត” ឬ “មិនពេញចិត្តសោះ”។

មានការប្រៀបធៀបរវាងក្រុមនៃអ្នកផ្តល់សម្ភាសន៍ ដែលប្រាប់អំពីតួលេខ យោងទៅតាមចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេ (ក្រុមដែលមិនត្រូវបានជូនដំណឹង) និងក្រុមអ្នកដែលត្រូវបានជូនដំណឹងក្នុងរយៈពេលនៃការធ្វើសម្ភាសន៍ (ក្រុមដែលត្រូវបានជូនដំណឹង)។ ក្រុមដែលត្រូវបានជូនដំណឹងដោយអត្ថបទដើមទំនងជា “មិនពេញចិត្ត” ឬ “មិនពេញចិត្តសោះ” តិចជាងក្រុមផ្សេងៗទៀត ពោលគឺ១៦.៧ភាគរយ បើប្រៀបធៀបជាមួយនឹង៣៦.៦ភាគរយ ហើយក៏ “ពេញចិត្ត” ឬ “ពេញចិត្តណាស់” ច្រើនជាងក្រុមផ្សេងៗទៀត ពោលគឺ ៦៩.៧ភាគរយ បើប្រៀបធៀបទៅនឹង៥៦ភាគរយ។

**Figure 17: Satisfaction with the sentence against Duch as reported by the participants**




មានការសាកសួរបន្ថែមទៀតអំពីការយល់ឃើញចំពោះសាលក្រមដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ៣៦.៧ភាគរយនិយាយថា វា “មិនស្រាល ហើយក៏មិនធ្ងន់” ១៦.៩ភាគរយចាត់ទុកថា “ស្រាល” ១៧.៨ភាគរយថា “ស្រាលពេក” និងសល់ប៉ុន្មានទៀតគិតថា វា “ធ្ងន់ធ្ងរ” (២០.៩%) ឬ ៧.៦% ថា “ធ្ងន់ធ្ងរណាស់” (គ្មានទិន្នន័យបង្ហាញ)។

ក្រុមកណ្តាលភាគច្រើនដែលគិតថាការកាត់ទោសមិនស្រាល តែក៏មិនធ្ងន់នោះ រួមជាមួយនឹងការពេញចិត្តនឹងសាលក្រមនៅកម្រិតខ្ពស់ជាទូទៅ ដូចបានបង្ហាញខាងលើ អាចចង្អុលបង្ហាញថា

រយៈពេលជាប់ពន្ធនាគារត្រូវបានពិចារណាថាសមរម្យ ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅក្នុងការអង្កេតនេះ។

ប្រតិកម្មខាងអារម្មណ៍ទៅនឹងការកាត់ទោសឌុច ជាញឹកញាប់ ត្រូវបានបញ្ជាក់ថា មានលក្ខណៈវិជ្ជមាន ពីសំណាក់អ្នកផ្តល់សម្ភាសន៍ ក្នុងនោះមានការពេញចិត្ត ការធូរស្បើយ និងមោទនភាពជាដើម។ ប្រតិកម្មអវិជ្ជមានខាងអារម្មណ៍ ដូចជាការខឹងសម្បារ ឬការខកចិត្ត មានតិចតួច។

**Figure 18: Emotional reactions about the sentence as experienced by the respondents**

**What did you feel when you heard that Duch was sentenced to serve 19 more years in prison? (%)**




ដើម្បីចង់ដឹងថាតើការកាត់ទោសដូចម្តេច ដែលអ្នកផ្តល់សម្ភាសន៍គិតថាសមរម្យនោះ យើងខ្ញុំបានសួរពួកគេថាតើឌុចគួរតែកាត់ទោសប៉ុន្មានឆ្នាំទៀត បើយោងទៅតាមការយល់ឃើញអំពីគោលការណ៍យុត្តិធម៌ផ្ទាល់ខ្លួនរបស់ពួកគេ។ ចម្លើយបង្ហាញនូវគំរូបីដំណាក់កាល៖ ប្រមាណ២០ភាគរយជ្រើសរើសយករយៈពេលជាប់ពន្ធនាគារម្ភៃ១៩ឆ្នាំទៀត ដែលឌុចត្រូវជាប់គុក រីឯមួយភាគបួនទៀតគិតថា ឌុចគួរទទួលបានរយៈពេលជាប់ពន្ធនាគារក្បែរៗនឹងការកាត់ទោសរយៈពេល៣៥ឆ្នាំ ដែលមិនទាន់កាត់ចេញ ហើយភាគច្រើន ពួកគេនិយាយថា ៣០ឆ្នាំ តែក្រុមទីបីគាំទ្រឲ្យមានការកាត់ទោស៤០ឆ្នាំ ឬលើសហ្នឹងទៀត។

គួរឲ្យកត់សម្គាត់ អ្នកផ្តល់សម្ភាសន៍៣៩នាក់ (មិនរាប់បញ្ចូលក្នុងតួលេខនេះ)បដិសេធមិនព្រមផ្តល់តួលេខណាមួយឡើយ ហើយនិយាយថា ចង់ឃើញឌុចនៅក្នុងគុកអស់មួយជីវិត។

**Figure 19: Prison term of Duch that the participants wish for**

**To how many more years in jail should Duch have been sentenced? (%)**




ដូចជារូបឌុច [illegible] ចំពោះមុខសាធារណជន។ ដូច្នេះ អ្នកផ្តល់សម្ភាសន៍ត្រូវបានសាកសួរអំពីការយល់ឃើញនាពេលបច្ចុប្បន្នរបស់ពួកគេអំពីឌុច។

ស្ទើតែពាក់កណ្តាលនៃប៉ាន់គំរូក្នុងការអង្កេតនេះបានឯកភាពថា “ឌុចបានសុំឲ្យអភ័យទោសដោយស្មោះ”។ ប្រមាណម្នាក់ក្នុងចំណោមបីនាក់មិនឯកភាពទាំងស្រុងទៅនឹងឃ្លានេះទេ។ មានល្បាយដូចគ្នានេះដែរចំពោះសំណួរ ដែលថាតើពួកគេគិតថា “ឌុចពិតជាសោកស្តាយចំពោះអ្វីដែលគាត់បានប្រព្រឹត្តិក្នុងរបបខ្មែរក្រហមដែរឬទេ?”

អ្នកផ្តល់សម្ភាសន៍ឯកភាពច្រើនជាងទៅនឹងឃ្លាដែលថា “ឌុចបានសុំការអភ័យទោសចំពោះអ្វីដែលគាត់បានប្រព្រឹត្តិ” និង “ឌុចបានសារភាពកំហុសរបស់ខ្លួន”។

**Figure 20: Perception of Duch today as reported by the participants**

**What do you think about Duch today? Duch … (%)**



*ការយល់ឃើញអំពីអវតក និងសកម្មភាពពាក់ព័ន្ធផ្សេងៗ*

៩០ភាគរយនៃអ្នកផ្តល់សម្ភាសន៍ទាំងអស់និយាយថា ជាមួយនឹងចំណេះដឹងដែលពួកគេមាននាពេលបច្ចុប្បន្ននេះ ពួកគេនឹងដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាថ្មី ពោលគឺ៨៩.១ភាគរយនិយាយថា “ប្រាកដណាស់” និង៥.៨ភាគរយនិយាយថា “នឹងដាក់ពាក្យ” (គ្មានទិន្នន័យបង្ហាញ)។ ទោះជាយ៉ាងនេះក្តី ស្ទើតែពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍បារម្ភ យ៉ាងហោចណាស់ “តិចតួច” អំពីសុវត្ថិភាពផ្ទាល់ខ្លួន ជាលទ្ធផលនៃការដាក់ពាក្យរបស់ខ្លួន។

**Figure 20: Concerns about their personal safety as stated by the participants**
**Are you concerned about your personal safety as a result of your application as a Civil Party to the ECCC? (%)**




ភាគរយនិយាយថា ខ្លួនមិនដែលមានជួបប្រទះបញ្ហាអ្វីទេ ពាក់ព័ន្ធនឹងសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ ជាលទ្ធផលនៃសកម្មភាពរបស់ខ្លួនទាក់ទិននឹងអវតក។ ៩៦.៩ភាគរយក៏និយាយដែរថា ខ្លួនមិនបានជួបប្រទះបញ្ហា ពាក់ព័ន្ធនឹងអវតកឡើយ (គ្មានទិន្នន័យបង្ហាញ)។

មួយភាគបីនិយាយថា ពួកគេជឿជាក់ថា តុលាការធ្វើការឯករាជ្យ “ទាំងស្រុង” ពីឥទ្ធិពលផ្នែកខាងនយោបាយ។ ១០ភាគរយនិយាយថា ខ្លួនមិនជឿថាដូច្នេះសោះឡើយ និង១៨ភាគរយជឿលើឯករាជភាពរបស់តុលាការ តែ “តិចតួច”ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ៣៣ភាគរយជឿជាក់ទៅលើអវត្តមានទាំងស្រុងនៃឥទ្ធិពលខាងផ្នែកនយោបាយ ដែលជាលទ្ធផលយ៉ាងវិជ្ជមានក្នុងបរិបទកម្ពុជាដែលជាញឹកញាប់គ្មានការជឿទុកចិត្តលើតុលាការ[63] ចំណែកអ្នកផ្តល់សម្ភាសន៍ឯទៀតបង្ហាញថា ខ្លួនមិនមិនជឿជាក់លើឯករាជភាពទាំងស្រុងនៃតុលាការនេះឡើយ។

**Figure 21: Opinion on political influence as stated by the respondents**

**Do you believe the court acts independently from political influence? (%)**




## *ការត្រៀមខ្លួនចំពោះការផ្សះផ្សា*

ពីរភាគបីគិតថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សានៅកម្ពុជា និងស្ទើតែអ្នកផ្តល់សម្ភាសន៍ទាំងអស់ទៀតគិតថា នឹងរួមចំណែក យ៉ាងហោចណាស់ “ជាចំណែកណាមួយ”។ សំណួរដូចគ្នានេះដែរត្រូវបានសួរដល់អ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងការអង្កេតលើកទីមួយ ក្នុងឆ្នាំ២០០៨/២០០៩។

តួលេខនៃអ្នកដែលនិយាយថា តុលាការនេះនឹងមិនរួមចំណែកដល់ការផ្សះផ្សាមានខ្ពស់ជាងបន្តិច ក្នុងការអង្កេតលើកទីមួយ បើប្រៀបធៀបទៅនឹងការអង្កេតទីពីរ។

**Figure 22: Opinions on the ECCCs contribution to reconciliation as indicated by the participants**

**Do you think the ECCC will contribute to reconciliation in Cambodia? (%)**




63 Pham, P., Vinck, P., Balthazard, M., Hean, S. & Stover, E. (2009). So we will never forget. A population based Survey on Attitudes about Social Reconstruction and the Extraordinary Chambers in the Courts of Cambodia. Publication. Retrieved November 16, 2010: http://hrc.berkeley.edu/pdfs/So-We-Will-Never-Forget.pdf

ប្រតិកម្មទៅនឹងការជំនុំជម្រះក្តីឌុចអាចរួមចំណែកដែរនៅត្រង់ចំណុចនេះ។ អ្នកចូលរួមផ្តល់សម្ភាសន៍ត្រូវបានសាកសួរអំពីប្រភេទនៃផលប៉ះពាល់ ដែលដំណើរការជំនុំជម្រះមានលើការត្រៀមខ្លួនផ្សះផ្សារបស់ពួកគេជាមួយនឹងជនដៃដល់។

៤៨%និយាយថា ការជំនុំជម្រះមាន “ផលប៉ះពាល់វិជ្ជមានលើការត្រៀមខ្លួនរបស់ពួកគេក្នុងការផ្សះផ្សា” ខណៈដែល១៤ភាគរយនិយាយថា វាមាន “ផលប៉ះពាល់អវិជ្ជមាន” និង៣៨ភាគរយយល់ឃើញថា “ផលប៉ះពាល់អវិជ្ជមានក៏គ្មាន និងផលប៉ះពាល់វិជ្ជមានក៏គ្មាន”។

**Figure 23: The trials impact on readiness to reconcile as stated by the respondents**

**What impact has the trial against Duch on your readiness to reconcile with the perpetrators? (%)**




ភាគរយឆ្លើយថា ខ្លួនបានត្រៀមខ្លួន “ច្រេនហោយ”។ ត្រងចណុចនេះ គួរកតសម្គាលផងដេរថា ការត្រៀមខ្លួនក្នុងការផ្សះផ្សា មានការកើនឡើងក្នុងចំណោមប៉ាន់គំរូ ចាប់តាំងពីការអង្កេតលើកទីមួយក្នុងឆ្នាំ២០០៨/២០០៩មក។ ការប្រៀបធៀបនេះបង្ហាញថា ក្នុងរយៈពេលដ៏ខ្លីនៅចន្លោះការអង្កេតទាំងពីរ ការរីកចម្រើនដ៏គួរឲ្យកត់សម្គាល់មួយទៅរកការត្រៀមខ្លួនជាងមុនក្នុងការផ្សះផ្សាបានកើតមានឡើង ពោលគឺអំឡុងពេលដែលគ្របដណ្តប់ភាគច្រើននៃការជំនុំជម្រះជាសាធារណៈក្នុងរឿងក្តីទីមួយរបស់តុលាការនេះ។

**Figure 24: Readiness to reconcile as indicated by the respondents**

**Are you ready to reconcile with the former Khmer Rouge? (%)**




អ្នកចូលរួមផ្តល់សម្ភាសន៍ក៏ត្រូវបានសាកសួរថាតើមានអ្វីដែលពួកគេយល់ថាធុញថប់ដែរឬទេ ពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេទាក់ទងនឹងអវតក។ ៦៦.៩ភាគរយនិយាយថា គ្មានអ្វីដែលពួកគេយល់ថាធុញថប់ឡើយ (គ្មានទិន្នន័យបង្ហាញ)។ យ៉ាងណាមិញ ១៩.៦ភាគរយនៃអ្នកចូលរួមផ្តល់សម្ភាសន៍មានការរំខានអារម្មណ៍នឹងរយៈពេលដ៏វែងអន្លាយ ដែលតុលាការនេះបានប្រើប្រាស់។ ជាញឹកញាប់ ពួកគេបង្ហាញការបារម្ភថា ជនដៃដល់អាចស្លាប់ មុនពេលពួកគេត្រូវបានកាត់ទោស។ មានតែអ្នកចូលរួមផ្តល់សម្ភាសន៍ប៉ុន្មាននាក់ប៉ុណ្ណោះបារម្ភថា ការជំនុំជម្រះនឹងមិននាំមកនូវយុត្តិធម៌ឡើយ (៩.០%) ឬនិយាយថា វាជីកកកាយនូវព្រឹត្តិការណ៍នៃការឈឺចាប់ឡើងវិញ (២.២%) (គ្មានទិន្នន័យបង្ហាញ)។ បន្ថែមលើនេះទៀត អ្នកផ្តល់សម្ភាសន៍ត្រូវបានស្នើសុំយោបល់នានា ដែលពួកគេអាចផ្តល់បាន ដើម្បីធ្វើឲ្យការចូលរួមនៅអវតក មានលក្ខណៈងាយស្រួលជាងមុនសម្រាប់ពួកគេ។ ១៩.០ភាគរយនិយាយថា តុលាការគួរធ្វើការឲ្យលឿនជាងនេះទៀត ហើយកាត់ទោសជនដៃដល់ឲ្យបានឆាប់ៗ។ ប្រាំពីរភាគរយចង់ឲ្យគេអញ្ជើញទៅទស្សនាអវតក និងប្រមាណ៩ភាគរយទៀតក៏បានសុំជាថវិកា ដើម្បីជាសោហ៊ុយធ្វើដំណើរទៅ និងស្នាក់នៅភ្នំពេញ។ ថវិកា ម្ហូបអាហារ និងការទទួលបានការថែទាំសុខភាព ត្រូវបានសុំស្នើដោយអ្នកចូលរួមផ្តល់សម្ភាសន៍ប្រាំមួយភាគរយ និងបួនភាគរយក៏បាននិយាយថា សំណាងនឹងជួយដល់ពួកគេ។

អ្នកចូលរួមផ្តល់សម្ភាសន៍ខ្លះចង់ទទួលបានព័ត៌មានបន្ថែម (៥%) សកម្មភាពផ្សព្វផ្សាយនៅជិតផ្ទះសម្បែងខ្លួន (២%) និងនិយាយថា ពួកគេចង់ចូលរួមសវនាការរបស់តុលាការរាល់ថ្ងៃ (៩%)។ ទោះជាយ៉ាងនេះក្តី ស្ទើតែ៩០ភាគរយនិយាយថា គ្មានអ្វីដែលអាចជួយធ្វើឲ្យការចូលរួមនៅអវតកងាយស្រួលជាងមុនសម្រាប់ពួកគេឡើយ។

**Figure 25: Suggestions made by the respondents to make their participation easier**
**What would you suggest to make participation in the ECCC easier for you? (% of cases)**




*ធនធាន*

ការចូលរួមនៅអវតកក៏អាចជាឱកាសមួយឲ្យជនរងគ្រោះពិភាក្សារឿងរ៉ាវរបស់ខ្លួនបានផងដែរ ប៉ុន្តែ វាក៏អាចធ្វើឲ្យពួកគេរលឹកឃើញនូវព្រឹត្តិការណ៍ដ៏សែនឈឺចាប់ កាលនៅអតីតកាលផងដែរ។ ដូច្នេះ អ្នកចូលរួមផ្តល់សម្ភាសន៍ត្រូវបានសាកសួរអំពីធនធាន ដែលពួកគេអាចប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ ក្នុងការផ្សាំខ្លួនជាមួយនឹងការចងចាំ និងអារម្មណ៍ដ៏ជូរចត់ទាំងនេះ។ អ្នកផ្តល់សម្ភាសន៍ក្នុងប៉ាន់គំរូត្រូវបានសួរសំណួរបើកចំហមួយអំពីអ្នកដែលពួកគេទៅជួប នៅពេលដែលពួកគេគិតច្រើនអំពីរឿងរ៉ាវរបស់ខ្លួន កាលនៅសម័យខ្មែរក្រហម។

ភាគច្រើននៃអ្នកចូលរួមផ្តល់សម្ភាសន៍រាយការណ៍ថា ខ្លួនបាននិយាយជាមួយក្រុមគ្រួសារ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកផ្តល់សម្ភាសន៍និយាយតិចតួចបំផុតអំពីការជួបអ្នកជំនាញ ឬអាជ្ញាធរមូលដ្ឋាន។ ១៥ភាគរយនៃប៉ាន់គំរូរាយការណ៍ថា ពួកគេមិនបាននិយាយជាមួយអ្នកណាឡើយ។

**Figure 26: Approached persons as indicated by the participants**

**When you think too much about your experiences in Khmer Rouge time, to whom do you talk to? (% of cases)**




ខណៈដែលភាគច្រើននៃប៉ាន់គំរូ (៥៩.៧%) រាយការណ៍ថា គ្មានទីណាពិសេស ដែលពួកគេអាចទៅ នៅពេលគិតច្រើនអំពីរឿងរ៉ាវរបស់ខ្លួន ឯអ្នកផ្តល់សម្ភាសន៍ខ្លះទៀតថា ខ្លួនទៅវត្តអារ៉ាម ទៅរមណីយដ្ឋានធម្មជាតិ ឬទៅផ្ទះអ្នកជិតខាង។

**Figure 27: Places mentioned by the participants**

**When you think too much about the experiences you went through in Khmer Rouge time, are there any special places in or near your community you are going to? (% of cases)**



នៅពេលសាកសួរអំពីអ្នកដែលខ្លួននិយាយជាមួយអំពីរឿងរ៉ាវជូរចត់ កាលនៅសម័យខ្មែរក្រហម អ្នកផ្តល់សម្ភាសន៍ភាគច្រើនឆ្លើយថា ពួកគេនិយាយជាមួយក្រុមគ្រួសារ ឬអ្នករស់រានមានជីវិតផ្សេងទៀត ។ ប្រមាណប្រាំភាគរយក៏បានឆ្លើយថា ខ្លួននិយាយជាមួយអ្នកធ្វើការសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល ដែលអ្នកទាំងនោះក៏អាចផ្តល់ការគាំទ្រសុខភាពផ្លូវចិត្តដល់ពួកគេផងដែរ។

នៅពេលសួរថាតើពួកគេមានស្វែងរកជំនួយពីអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តដែរឬទេនោះ ៨៥.៤ ភាគរយឆ្លើយថា មិនបានទេ។ បើទោះជា នេះជាចំនួនភាគច្រើនយ៉ាងច្បាស់លាស់ក៏ដោយ វាក៏មានន័យថា ប្រមាណ១៥ភាគរយ (៣៣នាក់) ព្យាយាមទទួលការគាំទ្រពីអ្នកជំនាញសុខភាពផ្លូវចិត្ត (គ្មានទិន្នន័យបង្ហាញ)។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការអង្កេតនេះរាយការណ៍ថា ពួកគេទទួលបានការគាំទ្រសុខភាពផ្លូវចិត្តពីផ្តល់សេវានេះខុសៗគ្នាមួយចំនួន។ ក្នុងចំណោមអ្នកដែលបានរាយការណ៍ថា បានស្វែងរកការគាំទ្រសុខភាពផ្លូវចិត្ត ៣៦ភាគរយបានទៅរកអ្នកធ្វើការសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល។ អ្នកផ្តល់សម្ភាសន៍បីនាក់ប្រាប់ថា ខ្លួនទៅរកចាស់ទំុ ធ្វើជាប្រភពសម្រាប់ការជួយគាំទ្រសុខភាពផ្លូវចិត្ត។

**Figure 28: Sources of professional mental health support as reported by the participants**

**From which mental health provider do you seek support when you feel stressed due to your experiences during the Khmer Rouge regime? (% of cases)**




ក្នុងសំណួរប្រាំមួយបន្ទាប់នេះ អ្នកចូលរួមផ្តល់សម្ភាសន៍ត្រូវបានសាកសួរផ្ទាល់អំពីភាពញឹក-ញាប់នៃការទៅជួបអ្នកផ្តល់សេវាគាំទ្រផ្នែកចិត្តសង្គមខុសៗគ្នា នៅពេលដែលពួកគេមានអារម្មណ៍ធុញថប់ ដោយសារតែរឿងរ៉ាវរបស់ខ្លួន កាលនៅសម័យខ្មែរក្រហម។ ក្រុមអ្នកដែលគេទៅពិគ្រោះយោបល់ញឹកញាប់ជាងគេ គឺអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត និងបន្ទាប់មកអ្នកធ្វើការសហគមន៍ ដែលជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងព្រះសង្ឃ។ អ្នកស្ម័គ្រចិត្តផ្នែកសុខភាព គ្រូពេទ្យ និងគ្រូបុរាណត្រូវបាននិយាយតិចជាង។ បើប្រៀបធៀបទៅនឹងអ្នកផ្តល់សេវាគាំទ្រចិត្តសង្គមផ្សេងៗទៀត អ្នកចូលរួមផ្តល់សម្ភាសន៍ចង្អុលបង្ហាញថា ពួកគេនិយាយទៅកាន់អ្នករស់

រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀតញឹកញាប់ជាង នៅពេលពួកគេមានអារម្មណ៍ធុញថប់ដោយសារតែរឿងរ៉ាវពីអតីតរបស់ខ្លួន។

ខណៈមានតែ១៣ភាគរយឆ្លើយថា ពួកគេ “មិនដែល” និយាយទៅកាន់អ្នកនៅរស់រានមានជីវិតផ្សេងឡើយ យ៉ាងហោចណាស់ពាក់កណ្តាលនៃប៉ាន់គំរូឆ្លើយថា ពួកគេ “ជួនកាល” បាននិយាយទៅកាន់អ្នករស់រានមានជីវិតផ្សេង និង៣៦ភាគរយឆ្លើយថា ពួកគេបាននិយាយគ្នា “ញឹកញាប់”។

សង្ខេបមក នៅពេលដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការអង្កេតនេះ គិតច្រើនពេកអំពីរឿងរ៉ាវដ៏សែនឈឺចាប់របស់ខ្លួន កាលនៅរបបខ្មែរក្រហម ជាញឹកញាប់ ពួកគេនិយាយទៅកាន់ក្រុមគ្រួសារ ឬអ្នករស់រានមានជីវិតផ្សេងទៀត ប៉ុន្តែមួយចំនួនប៉ុណ្ណោះមានទីកន្លែងទៅ បន្ធូរអារម្មណ៍ និងមួយចំនួនតូចស្វែងរកជំនួយពីអ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត។

**Figure 29: Frequency of respondents talking with possible mental health providers How often do you talk to … when you feel stressed due to your experiences in Khmer Rouge time? (%)**




ក្រៅពីហ្នឹង អ្នកចូលរួមផ្តល់សម្ភាសន៍ក៏ត្រូវបានសាកសួរអំពីថាតើពួកគេគិតថា សកម្មភាពជាក់លាក់មួយចំនួនអាចជួយបន្ធូរបន្ថយការឈឺចាប់របស់ពួកគេកាលនៅសម័យខ្មែរក្រហមបានខ្លះដែរឬទេ។

ប្រពៃណីពុទ្ធសាសនានៃការរៀបចំបុណ្យឧទ្ទិសដល់ព្រលឹងអ្នកដែលបានស្លាប់ត្រូវបាន លើកឡើងដោយអ្នកចូលរួមផ្តល់សម្ភាសន៍ភាគច្រើនថាជាពិធីដ៏មានប្រយោជន៍ ក្នុងការបន្សាំជាមួយនឹង

ការឈឺចាប់ផ្ទាល់ខ្លួនរបស់ពួកគេ។ បីក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបួននាក់បង្ហាញថា បុណ្យទានអាចជួយពួកគេ “គួរសម” ឬ “ច្រើនណាស់”។

មតិយោបល់អំពីថាតើការនិយាយទៅកាន់អតីតខ្មែរក្រហមនឹងធ្វើឲ្យមានអារម្មណ៍ធូរស្បើយពីរឿងរ៉ាវរបស់ខ្លួនដែរឬអត់នោះ គឺមានលក្ខណៈខុសប្លែកពីគ្នាយ៉ាងខ្លាំងក្នុងចំណោមប៉ាន់គំរូនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ខណៈដែល៤០ភាគរយគិតថា នេះអាចជួយដល់ពួកគេ “គួរសម” ឬ “ច្រើនណាស់” រីឯ៦០ភាគរយទៀតបង្ហាញថា នេះអាចគ្រាន់តែជួយ “តិចតួច” ឬ “អត់សោះ”។

ភាគច្រើននៃអ្នកចូលរួមផ្ដល់សម្ភាសន៍ (៦៩%)ចាត់ទុកការចងក្រងទុកជាឯកសារនៃរឿងរ៉ាវរបស់ពួកគេនៅរបបខ្មែរក្រហមថា “មានប្រយោជន៍គួរសម” ឬ “មានប្រយោជន៍ណាស់” ក្នុងការជួយបន្ធូរបន្ថយការឈឺចាប់ផ្ទាល់ខ្លួនរបស់ពួកគេ។ អ្នកផ្ដល់សម្ភាសន៍ប៉ុន្មាននាក់ប៉ុណ្ណោះ (៦%)គិតថា ការចងក្រងជាឯកសារមិនអាចជួយពួកគេឲ្យធូរស្បើយឡើយ។ ចំនួនដ៏ច្រើនចង់ឲ្យឯកសារទាំងនេះបើកចំហឲ្យសាធារណជន (៨៩%) ខណៈមានតែ១១ភាគរយប៉ុណ្ណោះមិនចង់ឲ្យផ្សព្វផ្សាយជាសាធារណៈ (គ្មានទិន្នន័យបង្ហាញ)។

**Figure 30: Opinions on possible measures to deal with own suffering as evaluated by the repondents**

**To what extend could it help you to … in order to deal with your painful past? (%)**




### *ចំណុចខ្វះខាតនៃការអង្កេត*

ដូចគ្នាផងដែរ ក្នុងការអង្កេតបន្ទាប់នេះ វាសំខាន់ក្នុងការគូសបញ្ជាក់ថា អ្នកចូលរួមផ្ដល់សម្ភាសន៍ជាក្រុមទីមួយនៃអ្នករស់រានមានជីវិត ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ មិនអាចបង្ហាញជាលក្ខណៈទូទៅនូវរបកគំហើញទាំងនេះឡើយ។ លទ្ធផលអាចខុសប្លែកគ្នាក្នុងក្រុមផ្សេងៗទៀតនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយ ដោយសមាគមអាដហុក និងអង្គការផ្សេងៗទៀត។

អ្នកផ្តល់សម្ភាសន៍ ពិសេសអ្នករស់រានមានជីវិតផ្ទាល់ពីរបបខ្មែរក្រហម ជាញឹកញាប់ ស្ថិតក្នុងជំនាន់មួយ ដែលខ្វះខាតការអប់រំជាមូលដ្ឋាន។ អនក្ខរភាពមានលក្ខណៈទូលំទូលាយ ពោលគឺពីរភាគបីនៃអ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះបង្ហាញថា ខ្លួនអាចអាន ឬសរសេរតិចតួចប៉ុណ្ណោះ ហើយភាគច្រើនមិនសូវដឹងអំពីពាក្យពេចន៍ប្រើប្រាស់នៅតុលាការ ឬពាក្យច្បាប់អ្វីឡើយ។ បន្ថែមលើនេះទៀត អ្នករស់រានមានជីវិតភាគច្រើនជាមនុស្សចាស់ ដែលមានបញ្ហាសុខភាពផង។ ជាក់ស្តែង កត្តាទាំងនេះអាចប៉ះពាល់ដល់សមត្ថភាពរបស់អ្នកផ្តល់សម្ភាសន៍ ក្នុងការស្តាប់ ឬយល់សំណួរ។ អ្នកធ្វើសម្ភាសន៍ត្រូវបានបណ្តុះបណ្តាលឲ្យសង្កេតមើលការយល់របស់អ្នកចូលរួមផ្តល់សម្ភាសន៍ និងសួរសំណួរច្រំដែលៗ នៅពេលចាំបាច់។

ការអង្កេតនេះត្រូវបានធ្វើភ្លាមៗបន្ទាប់ពីចេញដីកាដំណោះស្រាយសម្រាប់សំណុំរឿង០០២ ហើយអ្នកដាក់ពាក្យខ្លះទទួលបានដំណឹងអំពីការទទួលយកបាន និងការបដិសេធចំពោះពាក្យសុំរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ដំណើរការនៃការជូនដំណឹងដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងទំនងជាចំណាយពេលរហូតទល់ដើមឆ្នាំ២០១១។ នេះមានន័យថា មិនបានគ្រប់អ្នកចូលរួមផ្តល់សម្ភាសន៍ទាំងអស់នោះទេ ដែលទទួលបានការជូនដំណឹងអំពីស្ថានភាពនៃពាក្យសុំរបស់ខ្លួននៅអំឡុងពេលនៃការធ្វើបទសម្ភាសន៍។ វាអាចដែលថា ការទទួលស្គាល់ ឬការបដិសេធមុនពេលធ្វើបទសម្ភាសន៍អាចប៉ះពាល់ដល់របៀបដែលពួកគេយល់ឃើញអំពីអវតក។ បន្ថែមលើនេះទៀត ក្រុមផ្សេងមួយទៀតនៃអ្នកចូលរួមផ្តល់សម្ភាសន៍ ដែលមិនទាន់បានទទួលដំណឹង ចម្លើយរបស់ពួកគេអាចនឹងប៉ះពាល់ ដោយរយៈពេលដ៏យូរ ដែលពួកគេត្រូវរង់ចាំ តាំងពីពេលដែលពួកគេដាក់ពាក្យមក។

# ៥. ការពិភាក្សា

*ឥរិយាបទចំពោះអវតក*

ភ្លាមៗបន្ទាប់ពីការឈ្លានពានមកលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ការជំនុំជម្រះដ៏ខ្លីមួយត្រូវបានរៀបចំឡើងដោយរដ្ឋាភិបាល ដែលគ្រប់គ្រងដោយកងទ័ពវៀតណាម។ ប៉ុល ពត និងថ្នាក់ដឹកនាំផ្សេងៗទៀតត្រូវបានកាត់ទោសកំបាំងមុខ។ បន្ទាប់ពីចេញសាលាក្រមនេះហើយ គ្មានឃើញមានកិច្ចខិតខំប្រឹងប្រែងណាមួយក្នុងការចាប់ឲ្យជនដៃដល់នៃរបបខ្មែរក្រហមទទួលខុសត្រូវអ្វីឡើយ។ ជាញឹកញាប់ ជនរងគ្រោះត្រូវប្រឈមនឹងអ្វីដែលហៅថា វប្បធម៌និទណ្ឌភាព ពោលគឺអតីតនាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជា-ធិបតេយ្យ អៀង សារី ថែមទាំងទទួលបាននូវការលើកលែងទោស។ បច្ចុប្បន្ន គាត់ត្រូវបានចាប់ឲ្យទទួលខុសត្រូវនៅចំពោះមុខអវតក ចំពោះអ្វីដែលគេដឹងថាជាយុត្តិធម៌ត្រូវបានរង់ចាំអស់ពេលយ៉ាងយូរ ដោយជនរស់រានមានជីវិត។

សកម្មភាពផ្សព្វផ្សាយ ដែលមានបំណងជូនដំណឹងដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសអំពីអត្ថិភាពរបស់អវតក បានធានាថា វាត្រូវផ្សារភ្ជាប់ទៅនឹងមនសិការរបស់ប្រជាជនកម្ពុជា។ ដូចគ្នាផងដែរ អ្នកដែលមិនពាក់ព័ន្ធផ្ទាល់នឹងសកម្មភាពផ្សព្វផ្សាយក៏ត្រូវបានរកឃើញថាបានដឹងអំពីតុលាការផងដែរក្នុងចំណោមករណីប្រមាណ៨៥ភាគរយ។

ក្នុងការអង្កេតទីមួយក្នុងឆ្នាំ២០០៨/២០០៩ ចំនួនភាគច្រើនដ៏គួរឲ្យភ្ញាក់ផ្អើលនៃអ្នកចូលរួមផ្តល់សម្ភាសន៍ចង្អុលបង្ហាញថា ពួកគេត្រេកអរ ដែលមានតុលាការខ្មែរក្រហម។ មានចំនួនដ៏តិចតួចបំផុតនិយាយថា ខ្លួនត្រេកអរតែវាយឺតយ៉ាវពេក។

ក្នុងករណីប្រមាណ៩០ភាគរយ អ្នកចូលរួមផ្តល់សម្ភាសន៍និយាយថា ពួកគេមិនគិតថានៅមានជម្លោះរវាងខ្មែរក្រហម និងអ្នកដែលមិនមែនជាខ្មែរក្រហមនោះទេ។ ទោះជាយ៉ាងនេះក្តី ការភ័យខ្លាចចំពោះអតីតខ្មែរក្រហមនៅមាននៅឡើយក្នុងចំណោមមួយភាគបីនៃអ្នកចូលរួមផ្តល់សម្ភាសន៍។

ដូចមានពិភាក្សាបន្តិចទៀត ស្ទើតែគ្មានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-វេណីណាម្នាក់ជួបបញ្ហា ទាក់ទិននឹងការដាក់ពាក្យរបស់ខ្លួននៅអវតកឡើយ។ អវត្តមាននៃបទពិសោធន៍អវិជ្ជមានអាចជាធាតុផ្សំមួយ ដែលជម្រុញឲ្យមានការជឿទុកចិត្តកាន់តែច្រើន និងដែលធ្វើឲ្យមនុស្សម្នាចាត់ទុកអវតកជាអ្វីដែលសមនឹងតាមដានទៀត បើទោះជាមានការព្រួយបារម្ភក៏ដោយ។ ក៏មានការបង្ហាញអំពីការជឿទុកចិត្តផងដែរ ទាក់ទិននឹងការបារម្ភអំពីឥទ្ធិពលផ្នែកនយោបាយក្នុងកិច្ចការរបស់អវតក ដែលជាប្រធានបទមួយរួមដំណើរជាមួយតុលាការចាប់តាំងពីការចរចាដំបូងៗ រហូតមកទល់នឹងភាពស្រពិចស្រពិលនានានាពេលបច្ចុប្បន្ន ពាក់ព័ន្ធនឹងការស៊ើបអង្កេត ដែលអាចដឹកនាំទៅរកសំណុំរឿងបន្ថែមទៀតក្នុងពេលអនាគត។

នៅពេលសួរថាតើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា តុលាការដំណើរការដោយឯករាជ្យពីឥទ្ធិពលផ្នែកនយោបាយដែរឬអត់នោះ ប្រមាណបីភាគបួនជឿជាក់បែបនេះ "គួរសម" ឬ "ទាំងស្រុង"។

មួយក្នុងចំណោមបំណងប្រាថ្នានានានៃការបង្កើតអវតកនៅកម្ពុជា គឺដើម្បីជួយអភិវឌ្ឍប្រព័ន្ធតុលាការជាតិ ហើយធាតុផ្សំដ៏សំខាន់មួយគឺការសាងនូវទំនុកចិត្ត។ កេរ្តិ៍ឈ្មោះវិជ្ជមាននៃអវតកជាសញ្ញាណប្រកបដោយក្តីសង្ឃឹមមួយពាក់ព័ន្ធនឹងការសាងទំនុកចិត្តនេះ។ ជាញឹកញាប់ នេះក៏ត្រូវដើរទន្ទឹមគ្នាជាមួយនឹងការរំពឹងទុកដ៏ខ្ពស់ផងដែរ។

ភាគច្រើន អ្នកផ្តល់សម្ភាសន៍ចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ ក្នុងបំណងស្វែងរកយុត្តិធម៌ ហើយពួកគេត្រេកអរចំពោះអត្ថិភាពរបស់តុលាការ។ ទោះជាយ៉ាងនេះក្តី តួលេខដ៏គួរឲ្យកត់សម្គាល់នៃអ្នកផ្តល់សម្ភាសន៍មានរំខានចិត្តនឹងរយៈពេលដ៏យូរនៃដំណើរការនីតិវិធី និងបារម្ភថា ជនដៃដល់អាចស្លាប់មុនពេលពួកគេទទួលទោស។ សង្ខេបទៅ យើងរកឃើញថា កម្រិតដ៏ខ្ពស់នៃការត្រេកអរចំពោះអវតក ក្នុងចំណោោមអ្នករស់រានមានជីវិតពីរបប

ខ្មែរក្រហម។ បន្ថែមលើនេះទៀត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានរាយការណ៍អំពីផលវិបាកអវិជ្ជមានអ្វីទេ ពាក់ព័ន្ធនឹងការដាក់ពាក្យរបស់របស់ខ្លួននៅអវតក។ ហើយយើងខ្ញុំក៏មិនបានរកឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការអង្កេតនេះមិនពេញចិត្តជាមួយនឹងការងាររបស់តុលាការ ឬថាពួកគេមិនជឿជាក់តុលាការនេះឡើយ។ របកគំហើញនេះក៏ត្រូវបានគាំទ្រដោយឥរិយាបទរបស់អ្នកផ្តល់សម្ភាសន៍ចំពោះការជំនុំជម្រះរឿងក្តីឌុចដែរ។

*អ្វីដែលជម្រុញឲ្យអ្នករស់រានមានជីវិតចូលរួមនៅអវតក?*

សរុបទៅ ស្ទើរតែពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍មានអារម្មណ៍ព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេនៅកម្រិតមួយជាលទ្ធផលនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅអវតក។ មានហេតុផលចម្បងពីរ ដែលធ្វើឲ្យពួកគេដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បើទោះជាពួកគេបានបង្ហាញថា មានការព្រួយបារម្ភដ៏គួរឲ្យកត់សម្គាល់ក្តី។ ហេតុផលដែលបាននិយាយញឹកញាប់ជាងគេចំពោះការចូលរួមនៅអវតក ដូចបង្ហាញក្នុងការអង្កេតនេះ គឺដើម្បីស្វែងរកយុត្តិធម៌ និងដើម្បីសងសឹកចំពោះអ្វីដែលបានកើតឡើងចំពោះពួកគេក្នុងអំឡុងរបបខ្មែរក្រហម។

ដូច្នេះ បំណងប្រាថ្នាចង់សងសឹកនឹងអតីតខ្មែរក្រហម គឺនៅតែមាន ហើយត្រូវបានរាយការណ៍ញឹកញាប់ ពិសេសដោយអ្នកដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូចគ្នាផងដែរ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានរាយការណ៍ថា ខ្លួនបានអភ័យទោសឲ្យអតីតខ្មែរក្រហម តិចតួចជាងអ្នកដែលមិនបានដាក់ពាក្យនៅអវតក។ ក្នុងការអង្កេតនេះ មួយភាគបីនៃអ្នកដាក់ពាក្យបាននិយាយថា ពួកគេចង់ចូលរួម ក្នុងគោលបំណងសងសឹក។ នេះស្របគ្នានឹងរបកគំហើញដោយ Field និង ឈឹម ដែលបានរកឃើញថា

[64]Field, N. & Chhim, S. (2008). បំណងចង់សងសឹក និងឥរិយាបទចំពោះតុលាការខ្មែរក្រហមក្នុងចំណោមជនជាតិកម្ពុជា។. *J Loss Trauma*. 13(4), 352-372.

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានបំណងចូលរួម ឬផ្តល់សក្ខីកម្មនៅអវតក មានបំណងខ្លាំងជាងក្នុងការសងសឹកនឹងជនដៃដល់[64]។

## ការចូលរួមជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអវតក

ដូចបានបញ្ជាក់ខាងលើ បំណងចង់បានយុត្តិធម៌ និងបំណងចង់សងសឹកចំពោះអ្វី ដែលបានកើតឡើងក្នុងអំឡុងរបបខ្មែរក្រហមត្រូវបានលើកឡើងជាហេតុផលចម្បងនៃការដាក់ពាក្យនៅអវតក របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

បួនក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់ដែលបានផ្តល់សម្ភាសន៍ចង្អុលបង្ហាញថា ពួកគេបានតាមដានដំណើរការនីតិវិធីនៅអវតក។ នៅពេលនោះដំណើរការនីតិវិធីទាំងនេះ គឺភាគច្រើនជាសវនាការជំនុំជម្រះប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅឌុច ។ សវនាការក្នុងសំណុំរឿង០០១ បានប្រព្រឹត្តិទៅនៅចន្លោះខែមីនា ឆ្នាំ២០០៩ និងចុងខែកក្កដា ឆ្នាំ២០១០។ ភាគច្រើននៃអ្នកចូលរួមផ្តល់សម្ភាសន៍បង្ហាញថា ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន ជាប្រភពចម្បងនៃការទទួលព័ត៌មានអំពីដំណើរការជំនុំជម្រះ។ បន្ថែមលើនេះទៀត តួលេខដ៏គួរឲ្យកត់សម្គាល់ (ប្រមាណ ១៩%)រាយការណ៍ថាខ្លួនបានទៅចូលរួមទស្សនាសវនាការជំនុំជម្រះនៅតុលាការក្នុងរាជធានីភ្នំពេញ។

ការចូលរួមទស្សនាសវនាការជំនុំជម្រះទៀងទាត់មានលក្ខណៈកម្រ ដោយសារតែសោហ៊ុយធ្វើដំណើរ និងស្នាក់នៅរាជធានីភ្នំពេញ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបានផ្តល់សម្ភាសន៍ ស្នើសុំការដឹកជញ្ជូនទៅអវតក និងការគាំទ្រថវិកា សម្រាប់ចំណាយលើការធ្វើដំណើរ និងការស្នាក់នៅ នៅភ្នំពេញ ដើម្បីចូលរួមទស្សនាសវនាការ។ នេះជួយគូសបញ្ជាក់របកគំហើញរបស់យើងដែលថា ក្នុងការអង្កេតនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទំនងជាចាប់អារម្មណ៍នឹងអវតក ហើយចង់ឆ្លៀតយកឱកាសដ៏កម្រនេះមកតុលាការ ដើម្បីមើលសកម្មភាពសវនាការផ្ទាល់ភ្នែកពួកគេ។

ការផ្សព្វផ្សាយព័ត៌មានជាផ្លូវការដោយអវតកនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១០នេះពិតជាជួយសម្រួលដល់ទម្រង់នៃការចូលរួមរបស់ជនរងគ្រោះ។ តុលាការចង្អុលបង្ហាញថា រហូតមកទល់ពេលហ្នឹង សាធារណជន១២០០០នាក់បានមកចូលរួមទស្សនាការជំនុំជម្រះក្នុងសំណុំរឿង០០១ និងបានបញ្ជាក់ថា ការដឹកជញ្ជូនតាមរថយន្តក្រុងដោយឥតគិតថ្លៃអាចត្រូវបានផ្តល់ជូនដល់អ្នកចង់ចូលរួម[65]។

នៅពេលសាកសួរអំពីអ្វីដែលគេយល់ថាធុញថប់ ចំពោះសកម្មភាពរបស់ពួកគេពាក់ព័ន្ធនឹងអវតក ច្រើនជាង៦ភាគរយនិយាយថា គ្មានអ្វីដែលគេគិតថា ធុញថប់ទេ។ ចម្លើយតែមួយដែលផ្តល់ដោយតួលេខដ៏ច្រើននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងប៉ាន់គំរូនេះ (ជិត១៥%)ថា អវតកចំណាយពេល

[65] Official ECCC news from July 22, 2009: http://www.eccc.gov.kh/english/news.view.aspx?doc_id=299

ច្រើនហួសហេតុ និងប្រមាណតួលេខដូចគ្នានេះដែរស្នើឲ្យពន្លឿនដំណើរការនីតិវិធី។ អ្នកផ្ដល់សម្ភាសន៍ត្រូវបានសាកសួរសំណួរបើកចំហមួយថា តើមានអ្វីដែលពួកគេអាចឲ្យយោបល់ដើម្បីធ្វើឲ្យការចូលរួមរបស់ពួកគេនៅអវតកងាយស្រួលជាងមុនដែរឬទេ។ ចម្លើយច្រើនជាងគេគឺ "គ្មានអ្វីផង"។ ដូច្នេះ វាហាក់ដូចជា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីគ្មានអនុសាសន៍អ្វី ដើម្បីធ្វើឲ្យប្រសើរឡើងនូវដំណើរការនីតិវិធីឡើយ ដែលមានន័យថា ពួកគេពេញចិត្ត។

ពាក់ព័ន្ធនឹងទំនាក់ទំនងនឹងមេធាវី យើងរកឃើញថា អ្នកដែលស្គាល់មេធាវីខ្លួន (៦១%) ត្រូវបានរកឃើញថា ពេញចិត្តនឹងមេធាវីរបស់ខ្លួន។ ភាគច្រើន ទំនាក់ទំនងជាមួយនឹងមេធាវីបានកើតឡើងច្រើនដឹង ប្រមាណ៨០ភាគរយបានជួបមេធាវីខ្លួនច្រើនជាងម្ដង និងជាការជួបផ្ទាល់។ គ្មានអ្នកផ្ដល់សម្ភាសន៍ណាម្នាក់ចង្អុលបង្ហាញថា ខ្លួនមិនពេញចិត្ត ខណៈដែលច្រើនជាងពាក់កណ្ដាលនៃអ្នកផ្ដល់សម្ភាសន៍បង្ហាញថា ពួកគេ "ពេញចិត្តខ្លាំង" នឹងមេធាវីរបស់ខ្លួន។

មិនត្រឹមតែទទួលបានការគាំទ្រពីមេធាវីប៉ុណ្ណោះទេ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការអង្កេតនេះក៏ទទួលបានការគាំទ្រផងដែរពីក្រុមគ្រួសារខ្លួន។ បីក្នុងចំណោមអ្នកផ្ដល់សម្ភាសន៍បួននាក់ទទួលអារម្មណ៍ថា មានការគាំទ្រដោយក្រុមគ្រួសារខ្លួនក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅអវតក។ ដូចគ្នានេះដែរ ក្រុមគ្រួសារជិតស្និតត្រូវបានជូនដំណឹងអំពីការដាក់ពាក្យដោយអ្នកដាក់ពាក្យភាគច្រើន។

ប្រតិកម្មរបស់ក្រុមគ្រួសារ នៅពេលពួកគេឮអំពីការដាក់ពាក្យ ត្រូវបានរាយការណ៍ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថាមានលក្ខណៈវិជ្ជមាន។ ប្រតិកម្មអព្យាក្រឹតក៏ត្រូវបានរាយការណ៍ញឹកញាប់ផងដែរ ប៉ុន្តែក៏មិនបានបញ្ជាក់អំពីប្រតិកម្មអវិជ្ជមានផងដែរ។

នៅពេលសាកសួរអំពីផលប៉ះពាល់អ្វីខ្លះដែលការចូលរួមរបស់ពួកគេនៅអវតកមានលើក្រុមគ្រួសាររបស់ពួកគេកន្លងមក ប្រមាណពាក់កណ្ដាលនៃអ្នកផ្ដល់សម្ភាសន៍និយាយថា ផលប៉ះពាល់វិជ្ជមានក៏គ្មាន ផលប៉ះពាល់អវិជ្ជមានក៏គ្មាន ខណៈដែលពាក់កណ្ដាលទៀតចាត់ទុកថាមានផលប៉ះពាល់វិជ្ជមាន។

របកគំហើញរបស់យើងកន្លងមកបង្ហាញថា អ្នកផ្ដល់សម្ភាសន៍ទំនងជាចាប់អារម្មណ៍នឹងតុលាការ និងថា ពួកគេទទួលបានការគាំទ្រដ៏ពេញចិត្តពីសំណាក់មេធាវី និងក្រុមគ្រួសារ។

នៅពេលសាកសួរអំពីសំណុំរឿង ដែលពួកគេបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីស្ទើរតែពាក់កណ្ដាលនៃប៉ាន់គំរូឆ្លើយថា ពួកគេមិនបានដឹងថាតើសំណុំរឿងណាមួយនោះទេ។ បើទោះជាក្នុងចំណោមអ្នកដែលត្រូវបានទទួលដំណឹងថាជាដើមបណ្ដឹងរដ្ឋប្បវេណីក្ដី អត្រានេះនៅតែខ្ពស់នៅឡើយ គឺមួយភាគបី។

ក្នុងទម្រង់បែបបទដំបូងដែលចាំបាច់ត្រូវដាក់ទៅតុលាការ ស្ទើរតែអ្នកដាក់ពាក្យគ្រប់រូបត្រូវបានស្នើឲ្យ "សូមគូសបញ្ជាក់តើដំណើរការនីតិវិធីណាមួយ ដែលអ្នកចង់ចូលរួម"[66]។ ជម្រើសមានតែត្រូវបង្ហាញសំណុំរឿង០០១ ឬសំណុំរឿង០០២ ឬសំណុំរឿងទាំងពីរ។

ការពន្យល់ដែលអាចធ្វើបានចំពោះបញ្ហានេះ គឺថា អ្នកផ្ដល់សម្ភាសន៍ខាងលើមិនបានបំពេញទម្រង់បែបបទដោយខ្លួនឯងទេ។

នេះទំនងមកពីលក្ខណៈស្មុគស្មាញនៃទម្រង់បែបបទតែម្តង ដែលប្រើពាក្យពេចន៍តុលាការច្រើន និងការសុំឲ្យរៀបរាប់ពិស្តារអំពីឧក្រិដ្ឋកម្មដែលបានចោទ ក៏ដូចជាអត្រាខ្ពស់នៃអនក្ខរជនក្នុងចំណោមប៉ាន់គំរូ។ ជាញឹកញាប់ បុគ្គលិកផ្សព្វផ្សាយអង្គការមិនមែនរដ្ឋាភិបាលបានប្រមូលព័ត៌មានចាំបាច់ៗ ក្នុងបទសម្ភាសន៍ជាមួយអ្នកដាក់ពាក្យ ហើយបំពេញទម្រង់បែបបទជាមួយអ្នកដាក់ពាក្យ។

រយៈពេលដ៏វែងរវាងការដាក់ពាក្យ និងបទសម្ភាសន៍ក៏អាចជាហេតុផលមួយ ដែលអ្នកចូលរួមផ្តល់សម្ភាសន៍មិនអាចចងចាំថាតើសំណុំរឿងណាមួយ ដែលពួកគេបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពិសេសប្រសិនបើអ្នកនោះមិនបានតាមដានការជំនុំជម្រះទៀតនោះ និងគ្មាននរណាទំនាក់ទំនងពួកគេ។

ចុងក្រោយ នៅពេលដែលអ្នកចូលរួមផ្តល់សម្ភាសន៍ត្រូវបានសាកសួរថាតើ ជាមួយនឹងចំណេះដឹងដែលខ្លួនមាននាបច្ចុប្បន្ន ពួកគេនឹងដាក់ពាក្យថ្មី ដើម្បីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឬអត់ ៨៥ភាគរយឆ្លើយថា ខ្លួននឹងដឹកដាក់ពាក្យជាថ្មី។

របកគំហើយរបស់យើងចង្អុលបង្ហាញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានការពេញចិត្តនឹងការចូលរួមរបស់ខ្លួននៅអវតក និងការគាំទ្រពីសំណាក់មេធាវី អង្គការមិនមែនរដ្ឋាភិបាល និងក្រុមគ្រួសារខ្លួន។ ការអភិវឌ្ឍមួយស្នើឡើងដោយអ្នកផ្តល់សម្ភាសន៍ នោះគឺការគាំទ្រកាន់តែទូលំទូលាយសម្រាប់ការទៅទស្សនាផ្ទាល់នៅអវតក និងសម្រាប់ការតាមដានសវនាការ។ បើទោះជាមានការពេញចិត្តកម្រិតខ្ពស់នឹងតុលាការ និងបណ្តាញគាំទ្ររបស់តុលាការក្តី របកគំហើញយើងខ្ញុំក៏បង្ហាញថា មានកង្វះខាតផ្នែកព័ត៌មានឬការយល់ដឹងស៊ីជម្រៅថែមទៀតអំពីនីតិវិធីរបស់អវតក សម្រាប់អ្នកចូលរួមផ្តល់សម្ភាសន៍ជាច្រើននាក់។

### *ការត្រៀមខ្លួនសម្រាប់ការផ្សះផ្សា*

បើទោះជាវាសំខាន់ក្នុងការប្រឆាំងនឹងវប្បធម៌និទណ្ឌភាពក្តី អវតកទទួលខុសត្រូវចំពោះតែអ្នកដែលត្រូវបានកំណត់ថាជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ តាមពិតនៅកម្ពុជា ជាច្រើននាក់នៅកំពុងប្រឈមមុខនឹងស្ថានភាពពិបាកនៅឡើយ ត្បិតអតីតជនដៃដល់កំពុងរស់នៅក្នុងភូមិជាមួយគ្នានៅឡើយ ហើយថែមទាំងកាន់តំណែងដែលមានអំណាចទៀតផង។ តួលេខនៃអ្នកដែលចាត់ទុកជា “អតីតខ្មែរក្រហម” គឺនៅមានច្រើននៅឡើយ។

យោងទៅលើកត្តានេះ ការអភ័យទោស និងការផ្សះផ្សាហាក់ដូចជាសំខាន់ក្នុងសង្គមកម្ពុជា ដើម្បីឆ្ពោះទៅរកស្ថានភាពមួយ ដែលជនរងគ្រោះ លែងភ័យខ្លាចអតីតជនដៃដល់ទៀត។

ច្រើនជាងពាក់កណ្តាលនៃអ្នកផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះ នៅមិនទាន់ត្រៀមខ្លួនផ្សះផ្សាជាមួយនឹងអតីតខ្មែរក្រហមនៅឡើយ ពោលគឺ ពីរភាគបីនៃអ្នកចូលរួមផ្តល់សម្ភាសន៍ចាត់ទុកថាខ្លួន “នៅមិនទាន់ត្រៀមខ្លួនទាល់តែសោះ” ឬ “មិនបានត្រៀមខ្លួន” ក្នុងការផ្សះផ្សា។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថែមទាំងបានត្រៀមខ្លួនតិចតួចចំពោះការផ្សះផ្សា។ ប្រមាណចំនួនដូចគ្នានេះនៃអ្នកចូលរួមផ្តល់សម្ភាសន៍ថ្លែងថា “គ្មានទាល់តែ” នៃការផ្សះផ្សាបានកើតឡើងក្នុងភូមិខ្លួន។

យ៉ាងណាមិញ ច្រើនគ្នាជឿជាក់ថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សា (៥៣.៩%) ពោលគឺក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តួលេខនេះមានកាន់តែខ្ពស់ (៥៨.១%)។ ការអង្កេតលើកទីពីរបង្ហាញនូវការវិវឌ្ឍដ៏គួរឲ្យចាប់អារម្មណ៍មួយពាក់ព័ន្ធនឹងការផ្សះផ្សា។ បើប្រៀបធៀបទៅនឹងភាគរយពីឆ្នាំ២០០៨/២០០៩ ក្នុងឆ្នាំ២០១០ តួលេខនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគិតថា អវតកនឹងរួមចំណែកដល់ការផ្សះផ្សាកើនឡើងបន្តិច ហើយបច្ចុប្បន្ននៅជិត៦០ភាគរយ។ រាប់ទាំងអ្នកដែលនិយាយថា អវតកនឹងរួមចំណែក "ជាចំណែកខ្លះ" ដល់ការផ្សះផ្សា ភាគរយបានកើនឡើងដល់៩៥ភាគរយក្នុងឆ្នាំ២០១០ បើប្រៀបធៀបទៅនឹង៩០ភាគរយក្នុងអំឡុងពេលនៃការអង្កេតលើកទីមួយ។ អាចសន្និតបានថា ការជំនុំជម្រះរឿងក្តីឌុច ប្រហែលជាមានឥទ្ធិពលទៅលើរបកគំហើញខាងលើពាក់ព័ន្ធនឹងការផ្សះផ្សា។

ស្ទើរតែពាក់កណ្តាលនៃប៉ាន់គំរូនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចង្អុលបង្ហាញថា ការជំនុំជម្រះមានផលប៉ះពាល់វិជ្ជមានលើការត្រៀមខ្លួនរបស់ពួកគេក្នុងការផ្សះផ្សា។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសាកសួរជាថ្មីអំពីការត្រៀមខ្លួនផ្ទាល់ខ្លួនរបស់ពួកគេក្នុងការផ្សះផ្សា។ ការប្រៀបធៀបជាមួយនឹងរបកគំហើញរបស់ការអង្កេតទីមួយ ត្រូវបានធ្វើឡើង ប្រមាណពីរឆ្នាំមុន បង្ហាញថា កម្រិតនៃការត្រៀមខ្លួនក្នុងការផ្សះផ្សាមានការកើនឡើង។

បើប្រៀបធៀងនឹង៥១ភាគរយ ដែលនិយាយថា ពួកគេមិនបានត្រៀមខ្លួន "ទាល់តែសោះ" ក្នុងការផ្សះផ្សាក្នុងឆ្នាំ២០០៨/២០០៩ មានតែ៣៩.៤ភាគរយនិយាយដូចគ្នានេះដែរក្នុងការអង្កេតទីពីរ ខណៈដែលតួលេខអ្នកដែលនិយាយថា "បានត្រៀមខ្លួនកម្រិតខ្ពស់" មានជិតនឹងពីរដង (គឺពី៩.៣"ទៅ១៧.៧%) និងភាគរយដែលបង្ហាញថា "បានត្រៀមខ្លួនទាំងស្រុង" មានតួលេខបីដងខ្ពស់ជាងមុន។

### *ចំណេះដឹង និងមតិយោបល់ អំពីការជំនុំជម្រះរឿងក្តី ឌុច*

ដូចបង្ហាញខាងលើ ចំនួនដ៏ច្រើននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងប៉ាន់គំរូនេះបង្ហាញថា ខ្លួនបានតាមដានដំណើរការនីតិវិធីរបស់អវតក។ ទោះជាយ៉ាងនេះក្តី មិនច្បាស់លាស់ទេថាញឹកញាប់ប៉ុណ្ណាដែលអ្នកចូលរួមផ្តល់សម្ភាសន៍បានប្រើប្រាស់ប្រភពខុសៗគ្នានៃព័ត៌មាន ដូច្នេះពិបាកនឹងនិយាយថាតើទូលំទូលាយប៉ុណ្ណា ដែលពួកគេអាចតាមដានការជំនុំជម្រះ។ នេះអាចជាមធ្យោបាយមួយក្នុងការពន្យល់អំពីមូលហេតុដែលប្រមាណ៨០ភាគរយបានបង្ហាញថា ពួកគេបានតាមដានការជំនុំជម្រះ ប៉ុន្តែតែប្រមាណ៤០ភាគរយប៉ុណ្ណោះនិយាយថា ពួកគេដឹងអំពីការដាក់ទោសរបស់ឌុច និងក្នុងចំណោមតែប្រមាណ៣០ភាគរយអាចផ្តល់តួលេខត្រឹមត្រូវនៃរយៈពេលដែលឌុចត្រូវជាប់ពន្ធនាគារ។

លទ្ធផលបង្ហាញថា ចំណេះដឹង និងការយល់ដឹងអំពីការជំនុំជម្រះ មិនត្រូវបានបែងចែកស្មើៗគ្នាក្នុងប៉ាន់គំរូនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សម្ភាសន៍ក្នុងការអង្កេតនេះឡើយ។ ខណៈដែល៦០ភាគរយមិនដឹងអំពីការកាត់ទោសរបស់ឌុច។ តួលេខដ៏គួរឲ្យកត់សម្គាល់នៃអ្នកផ្តល់

សម្ភាសន៍ដែលនៅសល់ មានចំណេះដឹងយ៉ាងពិស្តារអំពីការជំនុំជម្រះ និងដឹងអំពីសាលក្រមចុងក្រោយ ដែលត្រូវបានបន្ថយមកត្រឹម ១៩ឆ្នាំ (៣៩.៩%)។ ជាច្រើននាក់ក៏បានឆ្លើយថា ឌុចនៅតែត្រូវជាប់ពន្ធនាគារ៣៥ឆ្នាំ (២៣.៣%) ដែលនេះចង្អុលបង្ហាញថា អ្នកចូលរួមផ្តល់សម្ភាសន៍ច្រើននាក់ មិនយល់អំពីធាតុផ្សំនេះនៃសាលក្រម។ អ្នកចូលរួមផ្តល់សម្ភាសន៍ដែលនៅសល់ តាមពិតបានអះអាងថា ខ្លួនដឹងអំពីការកាត់ទោស ប៉ុន្តែបានផ្តល់តួលេខខុសទៅវិញ។ ដូច្នេះ វាហាក់ដូចជា ការជំនុំជម្រះត្រូវបានសង្កេតមើលជាមូលដ្ឋានទូលំទូលាយ ប៉ុន្តែមានតែក្រុមអ្នកផ្តល់សម្ភាសន៍ដ៏តូចប៉ុណ្ណោះបង្ហាញនូវការយល់ដឹងស៊ីជម្រៅអំពីដំណើរការនីតិវិធី។

អាចមានមូលហេតុមួយចំនួនចំពោះករណីនេះ។ ទីមួយ ហេដ្ឋារចនាសម្ព័ន្ធនៅតាមទីជនបទរបស់កម្ពុជាទទួលបានការអភិវឌ្ឍតិចតួច ដូច្នេះហើយ មិនបានគ្រប់គ្នាទេដែលទទួលបានការផ្សព្វផ្សាយ ដូចជាតាមរយៈទូរទស្សន៍ ឬវិទ្យុនោះ។ ទីពីរ អ្នកដែលមានលុយកាក់តិចតួចទំនងរស់នឹងតម្រូវការជាមូលដ្ឋានសម្រាប់ក្រុមគ្រួសាររបស់ខ្លួនជាជាងការតាមដានដំណើរការនីតិវិធី ជាអាទិភាព។ ទីបី របៀបដែលគេផ្សព្វផ្សាយព័ត៌មានអាចស្មុគស្មាញពេកសម្រាប់អ្នកខ្លះ ពិសេសចំពោះចាស់ៗ និងអ្នកដែលគ្មានចំណេះដឹង។

ហើយចុងក្រោយ ដោយហេតុថា អ្នកចូលរួមផ្តល់សម្ភាសន៍ជាច្រើននាក់ត្អូញត្អែរថា ដំណើរការនីតិវិធីរបស់តុលាការចំណាយពេលយូរខ្លាំងពេក (១៤.៦%) វាអាចថា អ្នកខ្លះលែងចាប់អារម្មណ៍ ហើយឈប់តាមដានដំណើរការនីតិវិធី។

ជាទូទៅ លទ្ធផលនៃសំណុំរឿង០០១ត្រូវបានមើលឃើញយ៉ាងវិជ្ជមាន។ ពីរក្នុងចំណោមអ្នកចូលរួមផ្តល់សម្ភាសន៍បីនាក់ពេញចិត្តនឹងការកាត់ទោស (៦៤% "ពេញចិត្ត" ឬ "ពេញចិត្តខ្លាំង")។ ក្រុមដ៏ធំក៏បានចាត់ទុកថា សាលក្រមមានលក្ខណៈមិនធ្ងន់ ហើយក៏មិនស្រាល (៣៦.៩%) ដែលអាចជាសូចនាករមួយបង្ហាញថា សាលក្រមត្រូវបានចាត់ទុកថា យុត្តិធម៌ ឬសមរម្យ។

ប្រមាណមួយភាគបួននៃអ្នកផ្តល់សម្ភាសន៍មិនពេញចិត្តការកាត់ទោស(២៤.៩% "មិនពេញចិត្ត"ឬ "មិនពេញចិត្តខ្លាំង")និងប្រមាណ១៨ភាគរយក៏និយាយថា ទោសស្រាលពេក។ ការពេញចិត្តនេះអាចទទួលឥទ្ធិពលពីការរំពឹងទុក ដែលប្រជាជនមានចំពោះការកាត់ទោស ពោលគឺ សម្រាប់អ្នកខ្លះអត្ថិភាពនៃសាលាក្រម គឺពួកគេពេញចិត្តណាស់ទៅហើយ ខណៈដែលអ្នកផ្សេងទៀតប្រាថ្នាឲ្យមានសាលក្រមដែលធ្ងន់ធ្ងរជាងនេះ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សម្ភាសន៍ត្រូវបានសាកសួរអំពីការកាត់ទោសដែលពួកគេពេញចិត្ត ដោយយោងទៅតាមគោលការណ៍យុត្តិធម៌ផ្ទាល់ខ្លួនរបស់ពួកគេ ដែលអាចផ្តល់នូវអ្វីដែលពួកគេរំពឹងទុក។ ទិន្នន័យបង្ហាញថា មនុស្សភាគច្រើនចង់កំណត់ការកាត់ទោសខ្ពស់ គឺចាប់ពី៣៥ឆ្នាំឡើងទៅការកាត់ទោសមួយជីវិត ដូច្នេះការរំពឹងទុកចំពោះការកាត់ទោសឌុច ទំនងជាខ្ពស់។ វាហាក់ដូចជា អ្នកផ្តល់សម្ភាសន៍ខ្លះដែលបង្ហាញថា ពួកគេពេញចិត្ត នៅតែគិតថា ឌុច គួរទទួលទោសច្រើនឆ្នាំជាងហ្នឹងទៀត។

ការពន្យល់ដែលអាចធ្វើទៅបានចំពោះករណីនេះគឺថា អ្នកទាំងនេះយល់អំពីការកាត់

ទោសសំអាងទៅលើកម្រិតនៃអង្គហេតុ ប៉ុន្តែតាមអារម្មណ៍ គឺមិនទទួលយកការកាត់ទោសនេះទេ។ក្នុងចំណោមប្រតិកម្មខាងអារម្មណ៍ភ្លាមៗក៏រួមមាន កំហឹង និងការខកចិត្តផងដែរ បើទោះជាភាគច្រើនមិនបង្ហាញអំពីអារម្មណ៍ទាំងនេះក៏ដោយ។ ប្រមាណមួយភាគបីខឹង "គួរសម" ឬថែមទាំងខឹងខ្លាំង និងមួយភាគបួនខកចិត្ត "គួរសម" ឬ "ខ្លាំងណាស់"។ ទោះយ៉ាងណាក៏ដោយ ប្រតិកម្មវិជ្ជមាន មានច្រើន។

*ប្រភពនៃការគាំទ្រផ្នែកចិត្តសង្គម*

អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមទំនងជាសាក្សី ឬជនរងគ្រោះនៃព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្ត។ ក្នុងចំណោមបទពិសោធន៍ពាក់ព័ន្ធនឹងខ្មែរក្រហម ដែលត្រូវបានរាយការណ៍ញឹកញាប់ជាងគេ ក្នុងការអង្កេតនេះ រួមមាន៖ កង្វះអាហារ ឬទឹក ការបង្ខំឲ្យធ្វើការ និងការជម្លៀសដោយបង្ខំ។ ការសិក្សាមួយចំនួនមុនៗបង្ហាញថា នៅកម្រិតខ្ពស់ ជនកម្ពុជាមានជំងឺសុខភាពផ្លូវចិត្ត ពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្ត[67,68]។

ក្នុងបរិបទនៃអវតក ការឈឺចាប់របស់ជនរងគ្រោះ និងការរឿងរ៉ាវដ៏សែនខ្លោចផ្សារបស់ពួកគេទទួលការចាប់អារម្មណ៍ពីគ្រប់គ្នា ហើយក៏កើតចេញជាចម្ងល់អំពីការព្យាបាលនិងការគាំទ្រផងដែរ ពិសេសទាក់ទងនឹងលទ្ធភាពនៃការផ្តល់សំណង ដែលត្រូវជាការប៉ះប៉ូវឲ្យព្យសនកម្មនានា ដែលទទួលរងកន្លងមក។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការអង្កេតនេះ ត្រូវបានសាកសួរអំពីប្រភពចម្បងនៃការគាំទ្រដល់ពួកគេ នៅពេលទទួលអារម្មណ៍រំជួលចិត្តខ្លាំងដោយអតីតកាលដ៏សែនឈឺចាប់របស់ពួកគេ។ ពួកគេរាយការណ៍ថា ខ្លួននិយាយតែជាមួយក្រុមគ្រួសារនិងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមដូចគ្នាប៉ុណ្ណោះ។

ក្រុមគ្រួសារដើរតួដ៏សំខាន់មួយក្នុងសង្គមកម្ពុជា ហើយដោយសារតែកង្វះខាតសេវាសង្គម សមាជិកក្រុមគ្រួសារត្រូវពឹងពាក់គ្នាទៅវិញទៅមក នៅពេលដែលត្រូវការនូវការគាំទ្រ។ បីភាគបួននៃអ្នកផ្តល់សម្ភាសន៍មានអារម្មណ៍ថាទទួលបានការគាំទ្រពីក្រុមគ្រួសារ ពាក់ព័ន្ធនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ("ខ្លាំងណាស់" ៣៩.១% និង "គួរសម" ៣៧.២%)។ ជាទូទៅ ក្រុមគ្រួសារត្រូវបានជូនដំណឹង និងគ្មានប្រតិកម្មអវិជ្ជមាន នៅពេលពួកគេដឹងអំពីការសម្រេចចិត្តរបស់អ្នកដាក់ពាក្យ។

នៅពេលគិតច្រើនអំពីរឿងរ៉ាវរបស់ខ្លួនកាលសម័យខ្មែរក្រហម អ្នកផ្តល់សម្ភាសន៍ភាគច្រើននិយាយថា ពួកគេគ្មានកន្លែងណាពិសេសដែលត្រូវទៅឡើយ ពោលគឺ៦០ភាគរយនៅផ្ទះ។ នេះធ្វើឲ្យតួនាទីរបស់ក្រុមគ្រួសារកាន់តែតានតឹង ត្បិតបន្ទុកទាំងស្រុងនៃការគាំទ្រដល់អ្នកនៅរស់រានមានជីវិត ភាគច្រើនគឺធ្លាក់ទៅលើក្រុមគ្រួសាររបស់ពួកគេ។ ចំណែកអ្នកនៅរស់រានមានជីវិតដទៃទៀត ជាក្រុមផ្សេងតែមួយដែលត្រូវបានរកឃើញក្នុងការអង្កេតនេះ ថាជាអ្នកនៅរស់រានមានជីវិតដូចគ្នា ជាអ្នកដែលពួកគេនិយាយជាមួយអំពីបទពិសោធន៍របស់ខ្លួនក្រៅពីក្រុមគ្រួសារ។

ការដែលធ្លាប់ឆ្លងកាត់ជោគវាសនាដូចគ្នាអាចធ្វើឲ្យងាយស្រួលដល់ពួកគេក្នុងការនិយាយគ្នាជាចំហ។ ៨៧ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែល

បានផ្តល់សម្ភាសន៍ បង្ហាញថា ជាញឹកញាប់ ឬ ជូនកាល ពួកគេនិយាយជាមួយអ្នកនៅរស់រានមានជីវិតផ្សេងទៀត។

របកគំហើញនេះក៏បង្កប់អត្ថន័យថា ការគាំទ្រសមាគមនៃអ្នកនៅរស់រានមានជីវិត និងវិធីសាស្ត្រជួយខ្លួនឯងអាចជាវិធានការដ៏មានប្រសិទ្ធភាពមួយ ក្នុងការបន្ធូរបន្ថយបន្ទុកពីក្រុមគ្រួសាររបស់ពួកគេ។

ការស្វែងរកជំនួយពីអ្នកជំនាញត្រូវបានរាយការណ៍តែដោយ១៥ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ក្នុងការអង្កេតនេះ។ ប្រភពចម្បងនៃការគាំទ្របែបនេះ គឺទទួលពីបុគ្គលិកសហគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល (៣៦.៤%) និង ១៥.២% និយាយថាអង្គការចិត្តសង្គមអន្តរវប្បធម៌ (អង្គការធីភីអូ កម្ពុជា)ជាអ្នកផ្តល់ការគាំទ្រដល់សហគមន៍នៅតាមតំបន់ខ្លះនៅកម្ពុជា។

របកគំហើញនេះគូសបញ្ជាក់យ៉ាងច្បាស់ថា ការគាំទ្រសុខភាពផ្លូវចិត្តជំនាញនៅតែមិនទាន់ពេញនិយមនៅកម្ពុជា។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាត់ទុកថា ជាក្រុមដែលងាយរងគ្រោះ និងជាការផ្តោតអារម្មណ៍ចម្បងសម្រាប់អ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត ជាជាងក្រុមដែលងាយរងគ្រោះផ្សេងៗទៀតក្នុងប្រទេសនេះ។ ជាក់ស្តែង មានខ្សែទូរស័ព្ទជំនួយសម្រាប់ផ្តល់ប្រឹក្សាពិសេសមួយ សម្រាប់ពួកគេផ្តល់ជូនដោយអង្គការធីភីអូ កម្ពុជា។

វិធានការ ដូចជា ខ្សែទូរស័ព្ទជំនួយជួយបង្កើនការទទួលបាននូវការគាំទ្រផ្នែកសុខភាពផ្លូវចិត្តជំនាញ ប៉ុន្តែមានតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលបានការគាំទ្រជំនាញនេះ ហើយនេះបង្ហាញថា រចនាសម្ព័ន្ធថែទាំសុខភាពមូលដ្ឋាននៅតាមតំបន់ជាច្រើន មិនមានផ្តល់ការគាំទ្រប្រភេទនេះឡើយ។

នៅកម្រិតសហគមន៍ មានអ្នកផ្សេងទៀតមួយចំនួន ដែលអាចផ្តល់ជាការគាំទ្របានខ្លះ។ ទោះជាយ៉ាងណាក្តី ពួកគេមិនត្រូវបានពិគ្រោះយោបល់ជាមួយទៀងទាត់ឡើយ។ ក្រុមទាំងនេះរួមមាន ព្រះសង្ឃ អាជ្ញាធរមូលដ្ឋាន ពេទ្យនៅតាមមណ្ឌលសុខភាព គ្រូពេទ្យបុរាណ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ។ នេះបង្ហាញថា មានរចនាសម្ព័ន្ធមូលដ្ឋានខ្លះ ដែលអាចត្រូវបានប្រើប្រាស់ដើម្បីអនុវត្តវិធានការនានា ដែលមានបំណងជួយគាំទ្រដល់អ្នកនៅរស់រានមានជីវិតក្នុងការជួយបន្ធូរបន្ថយអតីតកាលដ៏សែនឈឺចាប់របស់ពួកគេ។ បើទោះជាក្រុមដូចរៀបរាប់ខាងលើទំនងជាមានជំនាញនៅមានកម្រិតក្តី ពួកគេមិនត្រូវបានពិគ្រោះយោបល់ញឹកញាប់ដើម្បីជួយធានាឲ្យមាននូវបទអន្តរាគមន៍ទៀងទាត់ឡើយ។

ស្ទើរតែ៨៦ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សម្ភាសន៍ និយាយ "ញឹកញាប់" ឬ "ជូនកាល" ទៅកាន់អ្នកនៅរស់រានមានជីវិតផ្សេងទៀតអំពីបទពិសោធន៍ឈឺចាប់របស់ខ្លួន ដែលនេះហាក់ដូចជាវិធីសាស្ត្រដែលអាចទទួលជោគជ័យ ដោយពឹងផ្អែកបទអន្តរាគមន៍ផ្នែកចិត្តសង្គមទៅលើក្រុមអ្នកនៅរស់រានមានជីវិតដែលត្រូវបានពង្រឹងអំណាច ក្នុងការរៀបចំក្រុមជួយខ្លួនឯងទៀងទាត់មួយ។

*សំណាង*

ក្នុងការអង្កេតទីមួយ ប្រមាណ១៦ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សម្ភាសន៍ថ្លែងថា សំណងជាមូលហេតុមួយ ដែលពួកគេដាក់ពាក្យនៅអវតក។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម-បណ្តឹងរដ្ឋប្បវេណីចាត់ទុកថាសំណងសំខាន់បើប្រៀបធៀបនឹងអ្នកនៅរស់រានមានជីវិតដែលមិនបានដាក់ពាក្យនៅអវតក។ ដូច្នេះ សំណងហាក់ដូចជាការជម្រុញទឹកចិត្តដ៏សំខាន់មួយក្នុងការដាក់ពាក្យ អមនឹងការស្វែងរកយុត្តិធម៌ និងការចង់សងសឹក។

ប្រមាណ៦០ភាគរយនិយាយថា សំណងគួរត្រូវបានចំណាយដោយជនល្មើស ២១ភាគរយនិយាយថា រដ្ឋាភិបាល និងជិត១១ភាគរយថា សហគមន៍អន្តរជាតិ គួរចំណាយចំពោះសំណងទាំងនេះ។

ផ្ទុយទៅនឹងបទបញ្ញាផ្លូវការរបស់អវតក ៣៧ភាគរយទាមទារសំណងជាលក្ខណៈបុគ្គលនិងសំណងជាថវិកា។ ១៦ភាគរយនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញបំណងប្រាថ្នាចង់ធ្វើបុណ្យទានឲ្យអ្នកដែលបានស្លាប់ និងជនរងគ្រោះដែលនៅរស់រានមានជីវិត ហើយពួកគេចង់បាននេះច្រើនជាង បើប្រៀបធៀបទៅនឹងអ្នកដែលមិនបានដាក់ពាក្យ។

ក្នុងការអង្កេតទីពីរ ចំណុចបីដែលអាចភ្ជាប់ផ្ទាល់ទៅនឹងសំណង ត្រូវបានបង្ហាញដល់អ្នកចូលរួមផ្តល់សម្ភាសន៍ ក្នុងបំណងវាយតម្លៃការចាប់អារម្មណ៍របស់ពួកគេ។ វិធានការដែលអ្នកផ្តល់សម្ភាសន៍ភាគច្រើនចាត់ទុកថាជួយដល់ពួកគេនោះគឺ ការរៀបចំបុណ្យទាន។ ស្ទើរតែបីភាគបួននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សម្ភាសន៍ចាត់ទុកពិធីបុណ្យទានថា “ជាជំនួយយ៉ាងខ្លាំង” ឬ “ជាជំនួយគួរសម” ក្នុងការជួយបន្ធូរបន្ថយការឈឺចាប់របស់ខ្លួន។

របកគំហើញទីពីរបង្ហាញថា ៧០ភាគរយគិតថា ការចងក្រងទុកជាឯកសារនូវបទពិសោធន៍របស់ខ្លួនអាច “ជាជំនួយយ៉ាងខ្លាំង” ឬ “ជាជំនួយគួរសម” ពោលគឺប្រមាណ ៨៩ភាគរយក៏ចង់ឲ្យឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ដោយហេតុថា វិធានការទាំងនេះទំនងជាស្ថិតក្នុងអត្ថន័យនៃសំណងផ្លូវចិត្ត និងសមូហភាពនោះ វិធានការទាំងនេះគួរត្រូវបានពិចារណា ក្នុងវិធីសាស្ត្រនាពេលអនាគត ដែលពាក់ព័ន្ធនឹងការផ្តល់សំណង។

ការជួប និងពិភាក្សាជាមួយអតីតខ្មែរក្រហមត្រូវបានវាយតម្លៃថា មិនសូវមានប្រយោជន៍។ ទោះជាយ៉ាងនេះក្តី ៤០ភាគរយនៅតែចាត់ទុកនេះថា “ជាជំនួយយ៉ាងខ្លាំង” ឬ “ជាជំនួយគួរសម”។

សង្ខេបមក ពាក់ព័ន្ធនឹងសំណង យើងខ្ញុំរកឃើញថា ការរៀបចំពិធីបុណ្យទានឲ្យក្រុមគ្រួសារអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ក៏ដូចជា បទអន្តរាគមន៍ជាក្រុម ជាមួយនឹងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមឬក្រុមគ្រួសារផ្សេងទៀត ក្នុងនាមជាវិធានការចិត្តសង្គមមួយនឹងហាក់ដូចជាវិធីសាស្ត្រមួយ ដែលទំនងនឹងទទួលបានជោគជ័យ ក្នុងចំណោមប៉ាន់គំរូនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ-ប្បវេណី ដែលបានផ្តល់សម្ភាសន៍។

# ៦. ស្នេរ និងសេចក្តីថ្លែងអំណរគុណ

ស្នេរ:

**Nadine Stammel**
ជំនួយការផ្នែកស្រាវជ្រាវនៅមជ្ឈមណ្ឌលបែរឡាំងសម្រាប់ការព្យាបាលជនរងគ្រោះពីអំពើទារុណកម្ម និងជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Free University Berlin

**Sebastian Burchert**
និស្សិតបញ្ចប់ការសិក្សាផ្នែកចិត្តវិទ្យានៅសាកលវិទ្យាល័យ Greifswald University

**តាំង សុភាព**
ជំនួយការផ្នែកស្រាវជ្រាវនៅអង្គការចិត្តសង្គម អន្តរវប្បធម៌ កម្ពុជា

**Estelle Bockers**
ជំនួយការផ្នែកស្រាវជ្រាវនៅមជ្ឈមណ្ឌលបែរឡាំងសម្រាប់ការព្យាបាលជនរងគ្រោះពីអំពើទារុណកម្ម និងជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Free University Berlin

**Christine Knaevelsrud**
ប្រធានផ្នែកស្រាវជ្រាវនៅមជ្ឈមណ្ឌលបែរឡាំងសម្រាប់ការព្យាបាលជនរងគ្រោះពីអំពើទារុណកម្ម និងជាសាស្ត្រាចារ្យជំនួយនៅសាកលវិទ្យាល័យ Free University Berlin

## ការរួមចំណែករបស់ស្នេរ:

Nadine Stammel និង Christine Knaevelsrud បានរៀបចំ និងត្រួតពិនិត្យមើលការអង្កេតទាំងពីរ។ Nadine Stammel, Sebastian Burchert, សុភាព តាំង និង Estelle Bockers បានសម្របសម្រួលការអង្កេតនៅកម្ពុជា។ Nadine Stammel, Sebastian Burchert និង Estelle Bockers បានត្រួតពិនិត្យមើលអ្នកប្រមូលទិន្នន័យនៅតាមមូលដ្ឋាន។ Nadine Stammel, Sebastian Burchert និង សុភាព តាំង បានវិភាគលទ្ធផល និងសរសេររបាយការណ៍នេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការចិត្តសង្គម អន្តរវប្បធម៌ (ធីភីអូ កម្ពុជា) សម្រាប់កិច្ចសហការរបស់ពួកគេ។ ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ វេជ្ជ. ឈឹម សុធារ៉ា (អង្គការធីភីអូ កម្ពុជា)

និងកញ្ញា Judith Strasser ពីអង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (DED)។ អ្នកទាំងពីរបានផ្តល់នូវការគាំទ្រដ៏ធំធេង និងយោបល់ដ៏មានតម្លៃ ក្នុងការអនុវត្ត និងការរៀបចំការអង្កេតនៅកម្ពុជា។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគម Adhoc) ចំពោះការជួយគាំទ្រដ៏មានតម្លៃរបស់ពួកគេ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកធ្វើសម្ភាសន៍របស់យើងខ្ញុំ ក្នុងនោះរួមមាន ស៊ុន សូលីដា, ស្រ៊ុន សុខឃីម, ស៊ូស ឌីណា, ឡុក ធារី, សាង សឹុម, ភៀក ស៊ីណា, ឃឹម សុខឿន, ខេ ឡុងគាត, ហ៊ាយ វឌ្ឍនា និងទ្រី វាសនា ដែលធ្វើសម្ភាសន៍ទាំងអស់ដោយគ្មានការហត់នឿយ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់គ្នា ដែលបានចូលរួមដោយស្ម័គ្រចិត្តក្នុងការអង្កេតរបស់យើងខ្ញុំ។ ការសិក្សាស្រាវជ្រាវនេះនឹងមិនអាចដំណើរការទៅបានឡើយ ប្រសិនបើគ្មានកម្លាំងចិត្តនិងការបើកចំហរបស់ពួកគេ។

bzfo
Behandlungszentrum
für Folteropfer Berlin

Behandlungszentrum für Folteropfer e.V.
(Center for the Treatment of Torture Victims)
Turmstr. 21
10559 Berlin
Germany
Phone: +49-(0)30-303906-0
info@bzfo.de
www.bzfo.de

## IN COLLABORATION WITH

TPO
Transcultural Psychosocial Organization
Community Mental Health Programme

Transcultural Psychosocial Organization (TPO)
#2&4, Corner Hanoi & Oknha Vaing Street
Sang Kat Phnom Penh Thmey, Khan Sen Sok
PO Box: 1124, Phnom Penh
Cambodia
Phone: +855-(0)23-6366992
admin@tpocambodia.org
www.tpocambodia.org

## FUNDED BY

Auswärtiges Amt

German Ministry of Foreign Affairs

PSYCHOLOGY beyond BORDERS®